# សង្ខេបប្រតិបត្តិ

## ១. សេចក្តីផ្តើម

ផែនការមេនៃប្រទេសកម្ពុជាសំរាប់ការអភិវឌ្ឍថាមពល ឆ្នាំ២០០៦ ដែលបានធ្វើឡើងដោយមានការគាំទ្រពីធនាគារពិភពលោក បានជ្រើសទីតាំងរោងចក្រវារីអគ្គិសនីសំខាន់ៗចំនួន១៣កន្លែងជាអាទិភាព ដើម្បីធ្វើការអភិវឌ្ឍថាមពលរវាងឆ្នាំ២០០៧ និង២០២២។ ទីតាំងវារីអគ្គិសនីស្ទឹងតាតៃ ជាគំរោងអភិវឌ្ឍន៏ជាអាទិភាពមួយមាននៅក្នុងផែនការមេឆ្នាំ២០០៦។ វាស្ថិតនៅក្នុងបញ្ជីអភិវឌ្ឍន៏វារីអគ្គិសនី ដែលមានសក្តានុពលនៅក្នុងតំបន់ត្រីកោណរបស់ខេត្តកំពង់ស្ពឺ កោះកុង និងខេត្តពោធិសាត់។ គំរោងនេះបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) នៅក្នុងខែមករា ឆ្នាំ២០០៧ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) និងក្រុមហ៊ុនសាជីវកម្មគ្រឿងចក្រធុនធ្ងន់ជាតិចិន CHMCនៃសាធារណរដ្ឋប្រជាមានិតចិន។ គំរោងនេះធ្វើការសិក្សារៀបចំដោយក្រុមហ៊ុន CHMC/Cambodia Tatay Hydropower Limited ដែលជាក្រុមហ៊ុនវិនិយោគ/ម្ចាស់គំរោង។ នៅពេលបច្ចុប្បន្ននេះ ក្រុមហ៊ុន Northwest Hydro Consulting Engineers (NWH) ជាក្រុមហ៊ុនកំពុងសិក្សាប្លង់វិស្វកម្មលំអិត និងការអនុវត្តគំរោង។ ចំណែកក្រុមហ៊ុន ឃី ខនសាល់ធេន ខេមបូឌា (KCC) ដែលជាក្រុមហ៊ុនពិគ្រោះយោបល់កម្ពុជាក្នុងស្រុក ត្រូវបានជ្រើសយកដោយក្រុមហ៊ុន CHMC/CTHL ដើម្បីធ្វើការ សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

គោលបំណងចំបងរបស់គំរោង គឺទាញយកផលប្រយោជន៏ពីធនធានបរិស្ថាន ជាពិសេសធនធានទឹកពីស្ទឹងតាតៃ និង ស្ទឹងកែបនៅក្នុងខេត្តកោះកុង។ ទន្ទឹមនោះដែរ ទឹកដែលស្តាក់ទុកនៅក្នុងអាងស្តុកទឹក អាចជួយសំរួលកំពស់ទឹកជំនន់ធំៗនៅខ្សែទឹកខាងក្រោម អាចផ្តល់ទឹកសំរាប់សកម្មភាពកសិកម្មនានា និង ងាយស្រួលទាញយកប្រភពទឹក (ពុំចោតខ្លាំងដូចមុន) សំរាប់ការប្រើប្រាស់ក្នុងសកម្មភាពផ្សេងៗ ព្រមទាំងងាយស្រួលដល់សត្វព្រៃក្នុងតំបន់នោះ។ គោលបំណងនៃសេដ្ឋកិច្ចសង្គមរបស់គំរោងវារីអគ្គិសនីស្ទឹងតាតៃគឺ ដើម្បីបំពេញតំរូវការថាមពលសំរាប់រយៈពេលមធ្យម និងរយៈពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា។ គំរោងនេះក៏បានឆ្លើយតបដោយផ្ទាល់ទៅនឹងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអណត្តិទីបីដែលចែងថា÷ " ទិដ្ឋភាពសំខាន់បំផុតមួយក្នុងចំណោមទិដ្ឋភាពទាំងអស់នៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលគឺ ការអភិវឌ្ឍបន្ថែមនៃវិស័យថាមពលដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធិភាពទៅនឹងការកើនឡើងតំរូវការ និងធ្វើឱ្យថាមពលអគ្គិសនីមានតម្លៃថោក "។

ទំហំនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) គ្របដណ្តប់ទាំងគុណប្រយោជន៏បរិស្ថាននិងសង្គម និងហេតុប៉ះពាល់លេចចេញពីគ្រប់ទិដ្ឋភាពទាំងអស់របស់គំរោង នៅក្នុងការកំណត់ក្របខ័ណ្ឌធនធានបរិស្ថានដ៏ធំទូលាយ និងគុណតម្លៃរបស់វា ដូចជា *បរិស្ថានរូបសាស្រ្ត*- ដី ទឹក និងបរិយាកាស *បរិស្ថានជីវសាស្រ្ត*- សត្វ និងរុក្ខជាតិ ដែលរស់នៅលើដីនិងនៅក្នុងទឹក ព្រមជាមួយនឹងជំរករបស់ពួកវា *បរិស្ថានសង្គម*- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សេវាកម្មសុខុមាលភាព និងគ្រឿងបរិក្ខាបំរើឱ្យ ការងារ ការអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ព្រមទាំង តំបន់វប្បធម៌ វត្ថុបុរាណ និងគុណភាពនៃតម្លៃជីវិតរស់នៅ។

Draft

## ២. ការពណ៌នាពីគំរោង

គំរោងវារីអគ្គិសនីស្ទឹងតាតៃមានទីតាំងស្ថិតនៅក្នុងស្រុកថ្មបាំង និងស្រុកកោះកុង ខេត្តកោះកុង ប្រទេសកម្ពុជា។ មានចំងាយប្រមាណ ៣៥គ.ម ភាគខាងកើតនៃទីរួមខេត្តកោះកុង និងមានចំងាយប្រហែល ២៦០គ.ម ពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៤ និង ផ្លូវលេខ៤៨។ ទីតាំងអាងស្តុកទឹកមួយផ្នែកស្ថិតនៅលើស្ទឹងតាតៃ និងស្ទឹងកែប ក្នុងឃុំឫស្សីជ្រុំ ស្រុកថ្មបាំង និង មួយផ្នែកទៀតនៅលើស្ទឹងតាតៃ ក្នុងឃុំត្រពាំងរូង និងឃុំតាតៃក្រោម ស្រុកកោះកុង។ អាគារផលិតថាមពលអគ្គិសនីស្ថិតនៅចំងាយប្រហែល១៥គ.មខាងក្រោមទីតាំងទំនប់ និងស្ថិតក្នុងឃុំតាតៃក្រោមនៃស្រុកកោះកុង ហើយខ្សែបណ្តាញបញ្ជូនចរន្តដែលភ្ជាប់ពីអាគារផលិតថាមពលក្នុងឃុំតាតៃក្រោមនៃស្រុកកោះកុង ឆ្លងកាត់ឃុំឫស្សីជ្រុំ និងឃុំតាតៃលើនៃស្រុកថ្មបាំងខេត្តកោះកុង ឆ្ពោះទៅអនុស្ថានីយ៍អូរសោមក្នុងឃុំអូរសោមស្រុកវាលវែង ខេត្តពោធិសាត់ សូមមើលផែនទីទីតាំងភូមិសាស្ត្ររបស់គំរោង ដូចមានភ្ជាប់ខាងក្រោមនេះ។

**សមាសភាពសំខាន់ៗរបស់គំរោងមានពិពណ៌នាដូចខាងក្រោមៈ**

(១) **ទំនប់ទប់ទឹកៈ** ទំនប់មួយនៅលើស្ទឹងមេ (ស្ទឹងតាតៃ) និងទំនប់មួយទៀតនៅលើដៃស្ទឹង (ស្ទឹងកែប)។

**ក. ទំនប់លើស្ទឹងតាតៃ**

- កំពស់ខ្នងលើទំនប់ ២២០ ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ)
- កំពស់ទំនប់អតិបរមា ១១០ ម
- ប្រវែងខ្នងលើទំនប់ ៨៨២.៣ ម
- ទទឹងខ្នងលើទំនប់ ១០ ម

**ខ. ទំនប់លើស្ទឹងកែបៈ**

- កំពស់ខ្នងលើទំនប់ ២២០ ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ)
- កំពស់ទំនប់អតិបរមា ៧៧ ម
- ប្រវែងខ្នងលើទំនប់ ៧១៣.៥ ម
- ទទឹងខ្នងលើទំនប់ ១០ ម

Draft




ទីតាំងភូមិសាស្ត្ររបស់គំរោង

(២) **សំណង់បញ្ចេញទឹក:** សំណង់បង្ហូរទឹកមានទំនប់បង្ហៀរ (spillway) និងរូងក្រោមដីប្រភេទបង្ហៀរទឹកមានសំពាធខ្លាំង (pressure spillway tunnel).

- ទំនប់បង្ហៀរបើកមុខ៣ប្រឡោះត្រូវបានរៀបចំនៅលើច្រាំងមាត់ស្ទឹងកែបខាងឆ្វេង មានប្រឡាយភ្ជាប់ទៅអាងទឹកទាំងពីរ (approach channel) មានសំណង់បង្ហៀរទឹក (overflow weir) សំណង់ទំលាក់ទឹក (chute) និងឧបករណ៍ឬសំណង់ចាប់សំរាម (flip bucket)។ ទំនប់បង្ហៀរទឹកនេះមានប្រវែងសរុប៧០៧.៦ម។ បាតក្រោមប្រឡាយភ្ជាប់អាងទឹកទាំងពីរ គឺមានរយៈកំពស់ ១៨៧ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ)។ សំណង់បង្ហៀរទឹកគឺមានទំហំ ៣ x ១២ម ហើយមានកំពស់ខ្ពងលើ ១៩៣ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ) និងទំហំបើកមុខមាន ៣ x (១២ម x ២២ម)។
- រូងក្រោមដីប្រភេទបង្ហៀរទឹកមានសំពាធខ្លាំង (pressure spillway tunnel) វាជាប្រភេទរូងក្រោមដីដែលធន់នឹងសំពាធខ្លាំង ដែលមានកន្លែងទាញយកទឹកមួយ (intake) រូងក្រោមដីធន់នឹងសំពាធខ្លាំង (pressure tunnel) មានទ្វារបិទបើករាងរង្វង់ (radial gate) សំណង់ទំលាក់ទឹក (chute) និងឧបករណ៍ឬសំណង់ចាប់សំរាម (flip bucket)។ រូងក្រោមដីប្រភេទបង្ហៀរទឹកមានសំពាធខ្លាំងនេះមានប្រវែងសរុប៧៩០ម។ មានរយៈកំពស់បាត១៦០ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ) និងមានទំហំបើកបាន ៨.៥ម x ៩ម (ទទឹង x កំពស់)។ រូងបង្ហូរទឹកក្រោមដីធន់នឹងសំពាធខ្លាំងមានអង្កត់ផ្ចិតក្នុង៨.៥ម។ ផ្ទៃបាតរបស់បន្ទប់ទ្វារបិទបើក (service gate chamber) គឺមានរយៈកំពស់ ១៥២ម (ធៀបនឹងនីវ៉ូទឹកសមុទ្រ) និងមានទំហំបើកបាន ៧.៥ម x ៦.៥ម (ទទឹង x កំពស់)។

(៣) **ប្រព័ន្ធបង្កើតថាមពល:** ប្រព័ន្ធផលិតថាមពលមានកន្លែងទាញយកទឹកមួយកន្លែង (intake) រូងបង្ហូរទឹកក្រោមដីធន់នឹងសំពាធខ្លាំង (pressure headrace tunnel) មានបន្ទប់បង្កើនសំពាធទឹក (surge chamber) អាគារផលិតថាមពលអគ្គិសនីផ្ទាល់ដីនៅមាត់ស្ទឹងខាងស្តាំ (river-side ground powerhouse) និង ប្រឡាយបញ្ចេញទឹកខាងចុង (tailrace channel)។

- កន្លែងទាញយកទឹកទៅបង្កើតថាមពលត្រូវបានរៀបចំនៅលើច្រាំងខាងឆ្វេងស្ទឹងតាតៃ ជាមួយនឹងរបាំងការពារសំរាម និង ទ្វារទឹកធំ (ទទឹង៨ម × កំពស់៨ម) ដែលនឹងត្រូវបានប្រតិបត្តិដោយប្រដាប់ទាញលើកទ្វារនៅលើកំពូលនៃប៉ម។
- រូងបង្ហូរទឹកក្រោមដីធន់នឹងសំពាធខ្លាំង មានបណ្តោយប្រវែង ៩៨៤៦ម មានរាងមូលដែលមានអង្កត់ផ្ចិត៨ម ហើយជំរាលនៃរូងបង្ហូរក្រោមដីគឺ ៥‰ និងអាច បង្ហូរធារទឹកបាន ១៥១.៨ ម³/វិនាទី និងមានល្បឿន ៣.០២ ម/វិនាទី។
- បន្ទប់បង្កើនសំពាធទឹក throttled surge chamber មានជញ្ជាំងកំពស់១២០ម អង្កត់ផ្ចិតក្នុង ១៤ម (១៥ម ផ្នែកខាងលើ) ហើយបាតក្រោមនៅរយៈកំពស់ ១១៦.២២ម។ អង្កត់ផ្ចិតក្នុងនៃបំពង់ចូលមានទំហំ ៤.៤ម។ បំពង់មេនាំទឹកមានអង្កត់ផ្ចិតក្នុង៨ម និងមានល្បឿនហូរ ៣.០២ម /វិនាទី និង



Draft

បំពង់នាំទឹកទៅទួប៊ីន មានអង្កត់ផ្ចិតក្នុង ៣.១ម ជាមួយនឹងល្បឿនហូរ ៦.៧ម/វិនាទី។ ប្រវែងសរុបនៃបំពង់នាំទឹកទៅទួប៊ីន គឺប្រហែល១២៧០ម (បំពង់នាំទឹកទៅទួប៊ីនទី១)។

- អាគារផលិតថាមពលសង់ផ្ទាល់ដីមានទំហំ ( បណ្តោយ៦២ម × ទទឹង១៥.៥ម × កំពស់៣៩ម ) មានទីតាំងនៅលើច្រាំងស្ទឹង។ ទួប៊ីនបង្កើតថាមពលប្រភេទ Francis ៣គ្រឿង នឹងត្រូវតំឡើងនៅក្នុងអាគារផលិតថាមពល។ អាគារផលិតថាមពលផ្ទាល់ដីមាន អាគារធំមួយ សំណង់លយចេញមួយ សំណង់អាគារសំរាប់បញ្ចេញទឹកខាងចុង រាប់ទាំងអាគារសេវាកម្ម ប្រឡាយបញ្ចេញទឹកខាងចុង និងកន្លែងបំលែងចរន្តអគ្គិសនី។

(៤) **ខ្សែនាំចរន្តអគ្គិសនីពីកន្លែងបំលែងថាមពលទៅកាន់អនុស្ថានីយ៍អូរសោម:** ខ្សែនាំចរន្តអគ្គិសនីតង់ស្យុង២៣០គីឡូវ៉ុល នឹងត្រូវតំឡើងតភ្ជាប់ពីកន្លែងបំលែងថាមពលនៅក្បែរអាគារផលិតថាមពល ទៅកាន់អនុស្ថានីយ៍អូរសោមដែលមានចំងាយប្រមាណជា៦៥គ.ម។ ចំងាយពីបង្គោលភ្លើងមួយទៅបង្គោលភ្លើងមួយទៀតមានប្រវែងពី ៣០០-៤០០ម។

(៥) **សមាសភាពបន្ទាប់បន្សំផ្សេងៗទៀត:**

- កែលំអរផ្លូវថ្មបាំង ពីទីប្រសព្វនៃផ្លូវជាតិលេខ៤៨ ទៅចំណុចច្រកចូលនៃទីតាំងទំនប់ ដែលមានប្រវែងប្រហែល ៥,៣គ.ម។
- សាងសង់ផ្លូវចេញចូល ទៅទីតាំងទំនប់ដែលមានប្រវែងសរុប ៩.៨៥គ.ម និងមានទទឹង ៧ម។
- សាងសង់ផ្លូវចេញចូល ទៅអាគារផលិតថាមពលដែលមានប្រវែងសរុប៤,៥គ.ម និងទទឹង៧ម។

**ពេលវេលាគ្រោងសំរាប់អនុវត្តន៍គំរោងមានដូចខាងក្រោម÷**

- ដំណាក់កាលរៀបចំគំរោងមានរយៈពេល ១៨ខែ
- ដំណាក់កាលសាងសង់មានរយៈពេល ៤ឆ្នាំ
- រយៈពេលនៃប្រតិបត្តិការគំរោង ៣៧ឆ្នាំ

**សម្ភារៈផ្សេងៗបំរើឱ្យការសាងសង់គំរោងមានដូចជា ÷**

- ក្នុងការសាងសង់គំរោងត្រូវការស៊ីម៉ងត៍ ១៩០.២០០ តោន
- ផេះចេញពីរោងចក្រអគ្គិសនីដុតធ្យូង ៦៨.០០០ តោន
- ដែក ៤៣.៤០០ តោន
- ឈើ១២.០០០ ម$^{៣}$
- ម្សៅសំរាប់ផ្ទុះថ្ម ៩.២០០ តោន
- ប្រេងឥន្ធនៈ ៣៤.០០០ តោន
- ដី និងថ្មសំរាប់បង្ហាប់ធ្វើឃឿនទំនប់ ១៤.៩០២.៣០០ ម$^{៣}$
- សំភារៈផ្សេងទៀត ២០១.០០០ តោន

**តំរូវការកំលាំងពលកម្ម** - គំរោងត្រូវការកម្មករជាមធ្យមពី ៣.២០០ ទៅ៤.១០០ នាក់ ក្នុងកំឡុងពេលសាងសង់។ ចំនួនពិតប្រាកដនៃកំលាំងពលកម្មក្នុងស្រុក និងក្រៅស្រុកអាស្រ័យការងារជាក់ស្តែង ។

**សមត្ថភាពផលិតថាមពល**- សមត្ថភាពផលិតថាមពលសរុបគឺ ២៤៦MW ជាមួយការផលិតថាមពលប្រចាំឆ្នាំគឺ ៨៥៨.១៤ GWh និងម៉ោងប្រើប្រាស់ប្រចាំឆ្នាំគឺ ៣៤៨៨ម៉ោង។

**ទុនវិនិយោគសរុប**- ***គឺ ៥៤០ លានដុល្លា*** *អាមេរិក* ។ ការវិនិយោគគំរោងនេះ គឺជាប្រភេទ BOT- សាងសង់ ប្រតិបត្តិការ និងផ្ទេរ ។

## ៣. ការពណ៌នាពីបរិស្ថាន

### *៣.១. ធនធានរូបសាស្ត្រ*

- **<u>បរិយាកាស</u>**

អាកាសធាតុរបស់ប្រទេសកម្ពុជាមានលក្ខណៈជាអាកាសធាតុត្រូពិចម៉ូសុង ដែលមានរដូវសំខាន់ៗពីរគឺរដូវប្រាំង និងរដូវវស្សា ។ រដូវវស្សាចាប់ពី ខែឧសភា ដល់ ខែតុលា ហើយរដូវប្រាំងចាប់ផ្តើមនៅខែវិច្ឆិកា ដល់ខែមេសា។ កំរិតទឹកភ្លៀងធ្លាក់ជាមធ្យមប្រចាំឆ្នាំនៅស្ថានីយ៍ស្រុកកោះកុងក្នុងរយៈពេល១៤ឆ្នាំចុងក្រោយនេះគឺ ៣៣៦២ មម។ សីតុណ្ហភាពអតិបរមាមធ្យមប្រចាំឆ្នាំគឺ ៣១.៤-៣៣.៨ អង្សាសេ និងអប្បបរមាមធ្យមប្រចាំឆ្នាំគឺ ២១.៦-២២.៣ អង្សាសេ។ សីតុណ្ហភាពទាបបំផុត នៅស្ថានីយ៍ស្រុកកោះកុងគឺ ១៧ អង្សាសេ (ខែមករា និងខែកុម្ភៈ) និងអតិបរមាខ្ពស់បំផុតគឺ ៣៦.៥ អង្សាសេ (ខែមេសា) ។

- **<u>ជលវិទ្យា</u>**

តំបន់ផ្ទៃរងទឹកភ្លៀងនៃគំរោងវារីអគ្គិសនីស្ទឹងតាតៃគឺមានផ្ទៃសរុប១០៧៣គ.ម² ។ ធនធានជលសាស្ត្រនៅក្នុងតំបន់គំរោងមានស្ទឹង ឬដៃស្ទឹងសំខាន់ៗមានចំនួន៦ហូរចូលទៅក្នុងស្ទឹងតាតៃដែលវាំហូរនេះកាត់ក្នុងតំបន់គំរោង។ ដៃស្ទឹងទាំងនោះរួមមាន ស្ទឹងតូច អូរក្រយ៉ា ស្ទឹងតាតៃលើ ព្រែកវែក ស្ទឹងកែប និងស្ទឹងតាតៃខ្លួនឯង។ ទិន្នន័យវាំហូររបស់ស្ទឹងតាតៃ នៅទីតាំងទំនប់ (ពីឆ្នាំ១៩៩២ ដល់ ២០០១)បានបង្ហាញពីវាំហូរមធ្យមប្រចាំឆ្នាំគឺ:

| | **វាំហូរមធ្យមប្រចាំឆ្នាំ** | **រដូវប្រាំង (ធ្នូ ដល់ មេសា)** | **រដូវវស្សា(ឧសភា ដល់ តុលា)** |
|---|---|---|---|
| អតិបរមា (ម³/វិនាទី) | ៩៩.២៥ | ១៤.២៩ | ១៨៥.៦៣ |
| អប្បបរមា (ម³/វិនាទី) | ៤៩.៥៣ | ២.៦៥ | ៩៣.១៩ |
| មធ្យម (ម³/វិនាទី) | ៧០.០៩ | ៦.០៤ | ១២៩.៨៨ |

យោងតាមការកត់ត្រាកំរិតកំពស់ទឹកជំនន់នៅក្នុងស្ទឹងតាតៃផ្នែកខ្សែទឹកខាងក្រោមនៅស្ថានីយ៍ភូមិដូងឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ទិន្នន័យនេះបានមកពីមន្ទីរធនធានទឹកនៅក្នុងខេត្តកោះកុង បានបង្ហាញថាភាពខុសគ្នារវាងកំពស់ទឹក



Draft

អប្បបរមា និងអតិបរមាគឺតិចជាង ១ម លើកលែងតែជំនន់ខ្ពស់បំផុតពី២ទៅ៣ថ្ងៃក្នុងខែកក្កដា និងសីហា ដែលបណ្តាលមកពីភ្លៀងធ្លាក់យ៉ាងច្រើននៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀង។ ជាងនេះទៅទៀត កំពស់ទឹកទីនេះមានការប្រែប្រួលទៅតាមការជោរឬនាចនៃទឹកសមុទ្រដែលមានកំពស់មធ្យម ០,៥ម ។ ជាទូទៅគុណភាពទឹកក្នុងស្ទឹងទាំងពីរគឺ ស្អាតល្អសំរាប់ប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់នោះ ប៉ុន្តែគុណភាពទឹកមិនសូវល្អនៅក្នុងរដូវប្រាំងសំរាប់ការផ្គត់ផ្គង់ទឹកប្រើប្រាស់នៅតាមផ្ទះ។ Total Coliform និង BOD មានបរិមាណខ្ពស់ជាងកំរិតស្តង់ដា ជាពិសេសនៅក្នុងរដូវប្រាំង។ ជាងនេះទៅទៀតទឹកសមុទ្រមានឥទ្ធិពលរហូតដល់ខ្សែទឹកខាងក្រោមនៃអាគារផលិតថាមពល ធ្វើឱ្យជាតិអំបិលបានកើនឡើងនៅខ្សែទឹកខាងក្រោមនៃអាគារផលិតថាមពល។

- **<u>កំទេចកំណ</u>**

កំទេចកំណប្រចាំឆ្នាំនៅក្នុងអាងស្តុកទឹកគឺ ៥.៩៨៥តោន ក្នុងស្ទឹងមេ (ស្ទឹងតាតៃ) និង៣.១៥៤តោនក្នុងដៃស្ទឹង (ស្ទឹងកែប) វាមានបរិមាណតិចបំផុតប្រៀបធៀបទៅនឹងសមត្ថភាពអាងរបស់ស្ទឹងមេគឺ ២៦៦លានម៣ និងដៃស្ទឹងផ្សេង១ទៀតគឺ ១៣៨លានម៣។ មានន័យថាក្នុងរយៈពេល២០ឆ្នាំនៃប្រតិបត្តិការអាងស្តុកទឹកមានកំទេចកំណនៅក្នុងតំបន់អាងស្តុករបស់ស្ទឹងមេប្រមាណ ៨៨៩.០០០ម៣ ឬ ០,៣% និងដៃស្ទឹង ៨៧៥.០០០ម៣ ឬ០,៦%នៃសមត្ថភាពអាងស្តុកទឹក។

- **<u>ឋានលេខា</u>**

ឋានលេខានៅក្នុងតំបន់គំរោងភាគច្រើនបំផុតជាតំបន់ភ្នំ និងខ្ពង់រាបដែលចាប់ផ្តើមចោតខ្លាំងបន្តិចម្តងៗពីសមុទ្រនៃទិសនិរតី និងមានចំណោតទេរបន្តិចម្តងៗទៅផ្នែកកណ្តាលរបស់ប្រទេសទៅទិសឦសាន។ រយៈកំពស់ទាបបំផុតគឺចាប់ផ្តើមពីកំពស់១០ម៉ែត្រ (ធៀបនឹងនីវ៉ូទឹកសមុទ្រ) នៅផ្នែកខ្សែទឹកខាងក្រោមនៃទីតាំងអាគារផលិតថាមពលដែលបានស្នើដោយគំរោងរហូតទៅដល់រយៈកំពស់ខ្ពស់ជាង៦៤០ម៉ែត្រ (ធៀបនឹងនីវ៉ូទឹកសមុទ្រ) នៅផ្នែកខ្សែទឹកខាងលើនៃទីតាំងគំរោង។

- **<u>ភូគព្ភសាស្រ្ត និង រញ្ជួយដី</u>**

ផ្អែកតាមផែនទីភូគព្ភសាស្រ្តរបស់ប្រទេសកម្ពុជាដែលមានមាត្រដ្ឋាន ១:៥០០,០០០ បោះពុម្ពដោយការិយាល័យផែនទី នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឆ្នាំ ២០០១ ភូគព្ភសាស្រ្តនៅតំបន់គំរោងគ្របដណ្តប់ដោយ

(១) ថ្មភក់សម័យសូរ៉ាស៊ិក-ក្រេតាសេ (JCg),

(២) ដីឥដ្ឋសម័យសូរ៉ាស៊ិក-ក្រេតាសេ (JCa), និងថ្មក្លាំង (JCcg), និង

(៣) ល្បាប់ថ្មី (a2)។ គំនរបាសាល់ស័កទី៤ (β1), ថ្មរីយ៉ូលីតសម័យសូរ៉ាស៊ិក-ក្រេតាសេ (p2), ថ្មរីយ៉ូដាស៊ិតសម័យសូរ៉ាស៊ិក-ក្រេតាសេ (p2δ), និង ដេវ៉ូល្វូ-កាបូនីហ្វែ (a1/DH) ត្រូវបានរកឃើញនៅប៉ែកខាងលើនៃតំបន់គំរោង ។

តាមលទ្ធផលនៃការសិក្សាភូគព្ភសាស្ត្រនៅក្នុងតំបន់គំរោង (ដោយវិទ្យាស្ថាន Jikan Geotechnical, ខែកញ្ញា ឆ្នាំ២០០៧) បានរកឃើញថាបាតុភូតភូគព្ភរូបសាស្ត្រសំរាប់តំបន់គំរោងនេះគ្របដណ្តប់ដោយថ្មរងនូវអាកាសធាតុ និងពុកផុយមានរំហូរកំទេចថ្មប្រមូលផ្តុំជាផ្ទៃធំត្រូវបានរកឃើញ។ ជាងនេះទៅទៀត លទ្ធផលនៃការសិក្សាភូគព្ភសាស្ត្រនៅក្នុងតំបន់គំរោងបានរកឃើញថាបាតុភូតភូគព្ភរូបសាស្ត្រសំខាន់សំរាប់តំបន់គំរោងនេះដែលគ្របដណ្តប់ដោយថ្មរងសំណឹកដោយអាកាសធាតុ និងបំណាក់ស្រុតចាស់ៗ ។ ពុំមានការបាក់ឬរអិលដីទេ និងពុំមានប្រវត្តិរញ្ជួយដីដែរ ។

## ៣.២ ធនធានជីវសាស្ត្រ

- **ព្រៃឈើ**

ប្រភេទព្រៃឈើនៅក្នុងតំបន់គំរោងគឺបានគ្របដណ្តប់ដោយព្រៃស្រោង។ ព្រៃឫស្សីត្រូវបានរកឃើញនៅទីកន្លែងវាលដីទំនេរ នៅតាមច្រាំងទាំងសងខាងស្ទឹង និងមានដុះនៅលាយជាមួយព្រៃស្រោងរិចរិលផងដែរ។ ទោះជាយ៉ាងណាក៏ដោយព្រៃឫស្សីនេះគឺវាមានចំនួនតិចតួចប៉ុណ្ណោះបើប្រៀបធៀបទៅនឹងព្រៃស្រោង ប៉ុន្តែមានវាលស្មៅដែលមានតម្លៃសំរាប់ជាចំណីអាហារសត្វព្រៃ និងជាជំរកសត្វជាទូទៅដ៏ល្អ។ មានដើមឈើចំនួន ១០៩ប្រភេទ បានរកឃើញនៅក្នុងតំបន់គំរោងដោយមានទំហំមុខកាត់តូចៗចាប់ពី១០០-២០០ម.ម គឺមានប្រហែលជា ៧០%នៃចំនួនដើមឈើសរុបទាំងអស់។ មានកូនឈើតូចៗជាច្រើនដែលមានមុខកាត់តូចជាង ៥០ម.ម មិនត្រូវរាប់បញ្ចូលទេ។ តំបន់គំរោងពុំសូវមានឈើប្រណិត និងឈើមានតំលៃនោះទេ ព្រោះរងការកាប់ធ្វើអាជីវកម្មតាំងពី ១៩៩៣-២០០២ ។ ប្រភេទដើមឈើទាំង ១០៩ប្រភេទ មានរៀបរាប់ពិស្តារនៅក្នុងតារាងឧបសម្ព័នទី៥។

- **<u>សត្វព្រៃ</u>**

យោងតាមរបាយការណ៍សិក្សាមុនៗ ដោយអង្គការអភិរក្សអន្តរជាតិ CI និងរដ្ឋបាលព្រៃឈើ FA ហើយនៅពេលថ្មីៗនេះបានសិក្សាស្រាវជ្រាវដោយអង្គការ Wildlife Alliance និងរដ្ឋបាលព្រៃឈើ FA ទៅលើដែនជំរកសត្វព្រៃក្នុងតំបន់ជួរភ្នំកាដាម៉ុមភាគកណ្តាល និងតំបន់គំរោង បានរកឃើញសត្វជាច្រើនប្រភេទដូចជា ថនិកសត្វ ល្មូន មណ្ឌុកសត្វ និងបក្សី ដែលមានវត្តមាននៅទីនេះ និងមានសត្វមួយចំនួនជាប្រភេទកំពុងរងគ្រោះ និងងាយរងគ្រោះ ដូចជា ដំរី ក្រពើភ្នំ ឆ្កែព្រៃ ខ្លាឃ្មុំ និងខ្លា។ ជ្រូកព្រៃ ឈ្លូស ប្រើស និងសំពោចដែលជាសត្វព្រៃសំបូរបំផុតនៅតំបន់នេះ។

- **<u>ត្រី និងសត្វដែលរស់នៅក្នុងទឹក</u>**

នៅក្នុងឆ្នាំ ២០០១ ការចុះអង្កេតវាយតម្លៃត្រូវបានធ្វើឡើងនៅក្នុងស្ទឹងបីនៅក្នុងខេត្តកោះកុង រួមមានស្ទឹងឫស្សីជ្រុំ ស្ទឹងកញ្ចោន និងស្ទឹងសាលាមន់ធន់ (Baird and Sok, 2002)។ លទ្ធផលពីការវាយតម្លៃបានបង្ហាញថា មានត្រី ៤៣ប្រភេទនៃ១៤អំបូរ ត្រូវបានរកឃើញ និង ៣៣ប្រភេទផ្សេងទៀតត្រូវបានកត់ត្រាថ្មីៗសំរាប់តំបន់ជួរភ្នំកាដាម៉ុម។



Draft

ម្យ៉ាងវិញទៀត លទ្ធផលសិក្សាក្នុងរដូវប្រាំងឆ្នាំ២០០៩នេះ បានបង្ហាញថាមានត្រីសមុទ្រសរុបចំនួន ៥៩ប្រភេទ ដែលមានវត្តមាននៅក្នុងតំបន់សិក្សារបស់គំរោង។ ក្នុងចំណោមត្រីសមុទ្រទាំងអស់នោះ មានពពួកក្តាមនៅក្នុងគ្រួសារពីរៈ ក្តាមសេស និង ក្តាមថ្ម។ ប្រភេទត្រីទឹកសាបសរុប ដែលកត់ត្រាក្នុងអំឡុងពេលសិក្សាមាន ៤០ប្រភេទ ដែលក្នុងនោះមានបង្កងទឹកសាបមួយប្រភេទផងដែរ។ មានអន្លង់ត្រីជាច្រើននៅតាមបណ្តោយដងស្ទឹង ដែលជាជំរកដ៏សំខាន់របស់ត្រីទឹកសាបនៅក្នុងស្ទឹងតាតៃ និងស្ទឹងកែប។ អន្លង់ទាំងនេះ គឺមានសារៈសំខាន់បំផុតសំរាប់ជំរកត្រីនាគផងដែរ។

មានព្រៃលិចទឹកពីរក្រុម មួយក្រុមគឺជាប្រភេទរស់នៅជាមួយព្រៃលិចទឹកសាប និងក្រុមមួយទៀតជាប្រភេទដែលរស់នៅជាមួយព្រៃលិចទឹកប្រៃ។ មាន៦២ប្រភេទដែលរស់នៅជាមួយព្រៃលិចទឹកសាប និងមាន ៣៦ ប្រភេទរស់នៅជាមួយព្រៃលិចទឹកប្រៃទាំងអស់នេះត្រូវបានកត់ត្រាអំឡុងពេលចុះអង្កេតតាមដាននៅទីវាល និងការសំភាសន៍ជាមួយគ្រួសារអ្នកនេសាទ។

## ***៣.៣ ការអភិវឌ្ឍសេដ្ឋកិច្ច***

- **<u>វិស័យឧស្សាហកម្ម</u>**

នាពេលបច្ចុប្បន្ននេះពុំមានសកម្មភាពឧស្សាហកម្មធនធ្ងន់ និងធំៗមាននៅក្នុងខេត្តកោះកុងនេះទេ ដោយយោងតាមសៀវភៅកំណត់ត្រាឧស្សាហកម្ម និងសិប្បកម្មរបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល។ ប៉ុន្តែមានសិប្បកម្មខ្នាតតូច និងការកែច្នៃម្ហូបអាហារ/ហាងលក់ចំនួន ២០៨កន្លែងជាលក្ខណៈគ្រួសារកំពុងប្រតិបត្តិក្នុងខេត្តទាំងមូល។ ជាទូទៅប្រភេទសិប្បកម្មនៅទីនោះ គឺការកែច្នៃចំណីអាហារ (ទឹកសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ ឡដុតនំ ផលិតទឹកកក) និងរោងជាងផ្សេងៗ។ គេពុំឃើញមានការធ្វើឧស្សាហកម្ម និងអាជីវកម្មរ៉ែនៅក្នុងតំបន់គំរោងនោះទេ លើកលែងតែអាជីវកម្មយកខ្សាច់ពីរកន្លែងរបស់ក្រុមហ៊ុនលីយ៉ុងផាត់ដែលកំពុងប្រតិបត្តិការនៅផ្នែកខ្សែទឹកខាងក្រោម នៃស្ទឹងតាតៃ (នៅខាងក្រោមនៃទីតាំងគំរោង) នេះបើយោងតាមការអង្កេតដល់ទីតាំងជាក់ស្តែង និងការពិភាក្សាជាមួយអាជ្ញាធរដែនដី និងជាមួយប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល។

- **<u>ការផ្គត់ផ្គង់ទឹក</u>**

ពុំមានបណ្តាញផ្គត់ផ្គង់ទឹកស្អាតនៅក្នុងឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ព្រមទាំងនៅក្នុងឃុំតាតៃក្រោម ស្រុកកោះកុងទេ។ ប្រភពផ្គត់ផ្គង់ទឹកសំខាន់ៗរបស់សហគមន៍នៅក្នុងតំបន់គំរោងគឺទឹកស្ទឹងតាតៃ អូរក្រយារ និងទឹកក្រោមដី។ ទឹកក្រោមដីគឺជាប្រភពទឹកដ៏សំខាន់សំរាប់ផ្គត់ផ្គង់ប្រើប្រាស់តាមគ្រួសារ។ ការប្រមូលទឹកភ្លៀងត្រូវបានប្រព្រឹត្តទៅនៅក្នុងរដូវវស្សាផងដែរសំរាប់ការប្រើប្រាស់តាមលំនៅដ្ឋានរបស់គ្រួសារមួយចំនួននៅក្នុងសហគមន៍នេះ។ យោងតាមការចុះសិក្សាអង្កេតដល់ទីកន្លែងបានរកឃើញប្រជាជនរស់នៅក្នុងឃុំឬស្សីជ្រុំបានប្រើប្រាស់ទឹកអណ្តូងខួង៦០% ទឹកលើដី ៣២.៥% និងអណ្តូងលូ ៧.៥% និងប្រជាជនដែលរស់នៅក្នុងឃុំតាតៃក្រោមប្រើប្រាស់ទឹកអណ្តូងលូ ៨២.៣% ទឹកចេញពីភ្នំ (Sprint)

Draft

៩.៧% អណ្តូងខួង ៥.៣% និងទឹកលើដី ២.៧%។ ពុំមានសកម្មភាពណាមួយបង្ហាញថា មានការប្រើប្រាស់បរិមាណទឹកច្រើនទេនៅក្នុងឃុំទាំងពីរនៃតំបន់គំរោង។

- **<u>ការផ្គត់ផ្គង់អគ្គិសនី</u>**

នៅពេលបច្ចុប្បន្ននេះ ខេត្តកោះកុងបាននាំភ្លើងអគ្គិសនីសរុប ៦មេហ្គាវ៉ាត់ ចូលមកពីប្រទេសថៃដើម្បីបម្រើតំរូវការក្នុងក្រុងខេមរៈភូមិន្ទ និងតំបន់ឧស្សាហកម្ម និងទេសចរណ៍ក្នុងស្រុកមណ្ឌលសីមា។ តម្លៃភ្លើងអគ្គិសនី ៦០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង សំរាប់អ្នកប្រើប្រាស់ទាំងអស់។ យោងតាមផែនការរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តត្រូវការថាមពលកើនឡើងដល់ ២៥ មេហ្គាវ៉ាត់ នៅឆ្នាំ២០១៥។

ម្យ៉ាងវិញទៀតតាមលទ្ធផលនៃការសិក្សាអង្កេតនៅទីវាលបានរកឃើញថា មានអ្នកផ្តល់អគ្គិសនីខ្នាតតូចមួយដែលបានតភ្ជាប់ទៅកាន់អ្នកប្រើប្រាស់ចំនួន ១០ផ្ទះ កំពុងធ្វើប្រតិបត្តិការនៅក្នុងឃុំឬស្សីជ្រុំ។ ការផ្គត់ផ្គង់ចរន្តអគ្គិសនីនេះ គឺប្រើម៉ាស៊ីនភ្លើង ហើយតំរូវឱ្យអ្នកប្រើប្រាស់បង់ថ្លៃ៣០០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ គ្រួសារភាគច្រើនប្រើប្រាស់ប្រេងកាតនិងទៀនសំរាប់ការអុជបំភ្លឺ។ គ្រួសារខ្លះទៀតបានប្រើប្រាស់អាគុយ។ ជាងនេះទៅទៀត មានរោងចក្រវារីអគ្គិសនីខ្នាតតូចដែលកំពុងសាងសង់នៅស្ទឹងតូចក្នុងភូមិគគីរជ្រុំចំនុចកណ្តាលនៃឃុំឬស្សីជ្រុំ។ រោងចក្រផលិតថាមពលនេះមានសមត្ថភាពផលិតបាន ១០-១៥គីឡូវ៉ុល និងថវិកាសាងសង់បានមកពីក្រុមហ៊ុន លី យ៉ុងផាត់។

- **<u>ការដឹកជញ្ជូន</u>**

ខេត្តកោះកុងតភ្ជាប់មករាជធានីភ្នំពេញ ដោយផ្លូវជាតិលេខ ៤ និងផ្លូវជាតិលេខ ៤៨ ដែលមានប្រវែងសរុប ២៨៥ គ.ម។ ផ្លូវជាតិលេខ ៤៨ ទើបតែធ្វើការកែលំអ និងដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០០៦។ ផ្លូវផ្សេងៗទៀតក្នុងខេត្តទាំងមូលបានធ្វើការកែលំអជារៀងរាល់ឆ្នាំ ប៉ុន្តែភាគច្រើនផ្លូវទាំងអស់នោះជាប្រភេទផ្លូវក្រាលគ្រួសក្រហម។ ខេត្តកោះកុងមានប្រលានយន្តហោះមួយស្ថិតក្នុងក្រុងខេមរៈភូមិន្ទ។ ប្រលានយន្តហោះនេះអាចចុះចតបានយន្តហោះខ្នាតតូចប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ននេះមិនដំណើរការទេ។

នៅក្នុងខេត្តកោះកុងពុំទាន់មានកំពង់ផែសមុទ្រនូវឡើយទេនាពេលបច្ចុប្បន្ននេះ។ ប៉ុន្តែមានផែតូចមួយស្ថិតនៅកណ្តាលនៃទីរួមខេត្តត្រូវបានប្រើសំរាប់ដឹកទំនិញ និងអ្នកដំណើររវាងខេត្តព្រះសីហនុ និងស្រុកផ្សេងៗទៀតក្នុងខេត្តកោះកុង និងមកពីខេត្តត្រាត (ប្រទេសថៃ)។ មានក្រុមហ៊ុនកប៉ាល់រ៉ឺយ៉ាល់តែមួយគត់ដែលនៅដំណើរការនាពេលបច្ចុប្បន្ននេះ ហើយចេញដំណើរម្តងក្នុងមួយថ្ងៃដែលធ្វើដំណើរទៅមកពីខេត្តកោះកុងទៅខេត្តព្រះសីហនុ។ យ៉ាងណាមិញពុំមានសកម្មភាពនាវាចរណ៍នៅខ្សែទឹកខាងលើនៃស្ទឹងតាតៃទេ (ចាប់ពីទីតាំងអាគារផលិតថាមពលទៅលើ) ពីព្រោះផ្ទាំងថ្មធំៗនៅក្នុងពោះស្ទឹង និងមានល្បាក់ទឹកធ្លាក់មួយចំនួនស្ថិតតាមស្ទឹងទាំងពីរ ជាពិសេសនៅផ្នែកខាងលើទីតាំងអាគារផលិតថាមពល ល្បាក់ទឹកធ្លាក់មានកំពស់រហូតដល់ទៅ ៥ម។



Draft

## ៣.៤. ធនធានសង្គម និង ធនធានវប្បធម៌

- **ប្រជាជន**

ខេត្តកោះកុងគឺជាខេត្តដែលស្ថិតនៅភាគនិរតីនៃប្រទេស និងមានព្រំប្រទល់ភាគខាងជើងជាប់ខេត្តពោធិសាត់ ភាគខាងលិចនិងខាងត្បូងជាប់ឈូងសមុទ្រថៃ និងភាគខាងកើតជាប់ខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ។ ហើយមានផ្ទៃដីសរុប ១១.១៦០គម$^{២}$ និងដង់ស៊ីតេប្រជាជនគឺ ១៣នាក់/គម$^{២}$ ។ ខេត្តកោះកុងបានបែងចែកជា៨ ស្រុក ៣៣ឃុំ និង ១៣៣ភូមិ (ទិន្នន័យខេត្តកោះកុង ឆ្នាំ២០០៨)។ យោងតាមទិន្នន័យជំរឿនប្រជាជនឆ្នាំ២០០៨ បាន បង្ហាញថាក្នុងខេត្តកោះកុងមានចំនួនគ្រួសារសរុប ២៨.៨៥៣គ្រួសារ និងចំនួនប្រជាជនសរុប ១៣៩.៧២២នាក់ ក្នុងនោះ មានស្រីចំនួន ៦៩.០៥៧នាក់ ឬ ៤៩.៤% ។ ចំនួនសមាជិកគ្រួសារមធ្យម ៤.៨នាក់។ មានចំនួន ១.១៩៩គ្រួសារ ឬ ៥.០៦២នាក់ កំពុងរស់នៅក្នុងស្រុកថ្មបាំង និង១.៥៩៤គ្រួសារ ឬ៧.៤៣៧នាក់ កំពុងរស់នៅក្នុងស្រុកកោះកុង នេះបើយោងតាមទិន្នន័យឃុំឆ្នាំ២០០៨។ លទ្ធផលបានពីការធ្វើសំភាសន៍ចំនួន ១៩៧គ្រួសារ ក្នុងឃុំទាំងពីរគឺឃុំឫស្សីជ្រុំ និងឃុំតាតៃក្រោមបានបង្ហាញថាប្រជាជនភាគច្រើននៅតំបន់នោះ គឺជាកសិករប្រហែល ៨៥% ស្ថិតក្នុងឃុំឫស្សីជ្រុំ និង ៦២%ស្ថិតក្នុងឃុំតាតៃក្រោម។ ក្រៅពីនេះគឺមន្ត្រីរាជការ អ្នកជំនួញខ្នាតតូច កម្មករ និងមានមុខរបរផ្សេងៗទៀត។

- **សេវាសុខភាព**

នៅក្នុងខេត្តកោះកុង ទីកន្លែងបំរើសេវាសុខភាពមាននៅក្នុងទីប្រជុំជនស្រុក និងទីរួមខេត្ត។ ទោះជាយ៉ាងណាក៏ ដោយក្នុងស្រុកថ្មបាំងមានប៉ុស្តិ៍សុខភាពមួយស្ថិតនៅក្នុងភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ។ ហើយមានប៉ុស្តិ៍សុខភាព មួយស្ថិតនៅក្នុងឃុំតាតៃក្រោម។ ស្ថានភាពប្រហាក់ប្រហែលនឹងប៉ុស្តិ៍សុខភាពនៅឃុំឫស្សីជ្រុំនេះដែរ ប្រជាជនរស់ នៅក្នុងតំបន់នេះពិបាកក្នុងការទទួលសេវាកម្មសុខភាពដោយសារ ចំនួនបុគ្គលិកសុខភាព ឱសថស្ថាន/ឱសថ និង មធ្យោបាយផ្សេងៗទៀតនៅមានកំរិត។ ក្នុងករណីមានអ្នកជម្ងឺធ្ងន់ធ្ងរ អ្នកជម្ងឺទាំងនោះត្រូវតែបញ្ជូនទៅមន្ទីរពេទ្យខេត្ត ដែលមានចំងាយប្រហែល ២០-៦០គ.ម ឆ្ងាយពីឃុំ។ មានជម្ងឺមួយចំនួនដែលទាក់ទងនឹងការប្រើប្រាស់ទឹកបានកើត ឡើងដោយសារខ្វះការយល់ដឹងពីអនាម័យ និងការសំអាតទឹកសំរាប់ផឹក ដាំស្ល និងការបោកគក់។ ទន្ទឹមនេះដែរនា ពេលបច្ចុប្បន្ននេះជំងឺគ្រុនចាញ់មានកំរិតខ្ពស់ក្នុងតំបន់គំរោងទោះបីបានថយចុះកាលពីឆ្នាំកន្លងទៅក៏ដោយ។ យោងតាម ទិន្នន័យកត់ត្រារបស់មណ្ឌលសុខភាពទាំងពីរខាងលើ។

- **ការងារអប់រំ**

មានសាលាបឋមសិក្សាចំនួនមួយខ្នង មាន៦បន្ទប់នៅក្នុងភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ។ សាលានេះស្ថិតនៅ ឆ្ងាយពីភូមិគគីរជ្រុំ និងមានចំងាយប្រហែល ២៥គ.ម ពីទីតាំងអាងស្តុកទឹកដែលបានស្នើ។ ពុំមានអនុវិទ្យាល័យ ឬ វិទ្យាល័យមាននៅក្នុងស្រុកថ្មបាំងនេះទេ។ ក្នុងស្ថានភាពដូចគ្នានេះដែរការកង្វះសេវាអប់រំនៅក្នុងតំបន់ ឃុំតាតៃក្រោម មានសាលាបឋមសិក្សាចំនួនមួយខ្នងដែលមាន៦បន្ទប់ប៉ុណ្ណោះ។ នៅពេលបញ្ចប់បឋមសិក្សាសិស្សមួយចំនួន ត្រូវទៅ

បន្តការសិក្សាថ្នាក់អនុវិទ្យាល័យនៅក្នុងទីរួមខេត្ត ។ សិស្សភាគច្រើនបានបោះបង់ការសិក្សាទាំងថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ដោយសារកង្វះសេវាកម្មអប់រំនៅក្នុងតំបន់។

- **លក្ខខណ្ឌសេដ្ឋកិច្ចសង្គម**

មានវិស័យសេដ្ឋកិច្ចចំបងចំនួន៣នៅក្នុងខេត្តកោះកុងៈ (១)វិស័យកសិកម្ម នេសាទ និងរុក្ខាប្រមាញ់ (២) ផលិតផលឧស្សាហកម្ម និង(៣)សេវាកម្មទូទៅរួមបញ្ចូលទាំងទេសចរណ៍។ អាស្រ័យដោយមានការកែលំអហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសបណ្តាញផ្លូវថ្នល់ និងសេវាទូរគមនាគមន៍ នោះនាំឱ្យមានការបង្កើតឡើងនូវសកម្មភាពអភិវឌ្ឍន៍ជាច្រើននៅក្នុងខេត្តកោះកុងជាពិសេសទាក់ទងទៅនឹងវិស័យកសិ-ឧស្សាហកម្ម និងវិស័យទេសចរណ៍ ។

ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍសេដ្ឋកិច្ចចំបងនៅក្នុងស្រុកថ្មបាំង គឺពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម ព្រៃឈើនិងអនុផលព្រៃឈើ។ ខណៈនោះដែរនៅក្នុងខេត្តកោះកុងក្រៅពីប្រកបរបរ កសិកម្ម ព្រៃឈើ និង អនុផលព្រៃឈើ នាពេលបច្ចុប្បន្ន មានកសិ-ឧស្សាហកម្ម សិប្បកម្ម និង ទេសចរណ៍។

ប្រភពប្រាក់ចំណូលទាំងអស់ឃើញថា នៅក្នុងឃុំឫស្សីជ្រុំប្រាក់ចំណូលមធ្យមគឺ ២.៤០០.០០០រៀល ឬ ៦០០ដុល្លាក្នុងមួយឆ្នាំក្នុងមួយគ្រួសារ។ រីឯឃុំតាតៃក្រោមវិញប្រាក់ចំណូលមធ្យមប្រហែល ៤.៨០០.០០០រៀល ឬ ១.២០០ដុល្លាក្នុងមួយឆ្នាំក្នុងមួយគ្រួសារ។ នេះបង្ហាញថាឃុំតាតៃក្រោមផ្នែកខ្សែទឹកខាងក្រោមនៃទីតាំងគំរោង មានសកម្មភាពសេដ្ឋកិច្ចច្រើនជាងផ្នែកខាងលើ ព្រោះមានទីតាំងស្ថិតនៅជាប់ផ្លូវជាតិ និងនៅជិតទីរួមខេត្ត ដូច្នេះងាយស្រួលរស់នៅតាមរយៈឱកាសការងារច្រើនជាងឃុំឫស្សីជ្រុំ។

- **មរតកវប្បធម៌**

មានវត្តអារាមមួយឈ្មោះថា "សិលាមុនីគីរីរង្សី " (ហៅថាវត្តថ្មបាំង) ស្ថិតនៅក្នុងភូមិត្រពាំងឈើត្រាវ មានចំងាយប្រហែល២៥គ.ម ពីទីតាំងអាងស្តុកទឹករបស់គំរោងវារីអគ្គិសនីស្ទឹងតាតៃ។ បន្ទាយថ្មាយមានចំងាយ ២៨ គ.ម នៅខ្សែទឹកខាងលើនៃតំបន់អាងស្តុកទឹក។

ពុំមានប្រាសាទ និងទីតាំងបុរាណសាស្ត្រនៅក្នុងតំបន់គំរោងវារីអគ្គិសនីស្ទឹងតាតៃទេ។ ព័ត៌មាននេះបានទទួលមកពីការអង្កេតជាក់ស្តែង និងព័ត៌មានមួយចំនួនបានប្រមូលពីអាជ្ញាធរមូលដ្ឋានព្រមទាំងស្ថាប័នដែលពាក់ព័ន្ធនៅក្នុងខេត្តកោះកុង ។

## ៤. ការវាយតម្លៃហេតុប៉ះពាល់

### *៤.១ សក្តានុពលផលប៉ះពាល់អវិជ្ជមាន និង វិធានការបន្ធូរបន្ថយ*

#### ក) ដំណាក់កាលមុនពេលសាងសង់



Draft

**<u>ទីតាំងគំរោង:</u>** ទីតាំងគំរោងនឹងមានហេតុប៉ះពាល់ទៅលើ (i) តំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៉ និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង និង (ii) តំបន់ព្រៃការពារអភិរក្សជីជំរាលជួរភ្នំក្រវាញភាគកណ្តាល និងជីវចំរុះ។ តំបន់ទាំងពីរនេះគឺមានសារៈសំខាន់ណាស់សំរាប់ជំរកសត្វព្រៃភាគខាងត្បូងនៃប្រទេសកម្ពុជា ហើយវាជាជំរកចុងក្រោយបំផុតមួយ នៃសត្វងាយរងគ្រោះ សត្វកំរ និងប្រភេទសត្វកំពុងរងគ្រោះនៅក្នុងតំបន់។

***វិធានការបន្ធូរបន្ថយ***

- *កំពស់ទំនប់នឹងបន្ថយឱ្យនៅទាបសមរម្យមួយ ដើម្បីកាត់បន្ថយផ្ទៃលិចទឹក*
- *បន្ទាត់នៃខ្សែបញ្ជូនចរន្តនឹងជ្រើសរើសទីតាំងឱ្យនៅជិតផ្លូវដែលមានស្រាប់*
- *រចនាប្លង់វិស្វកម្មរបស់គំរោងរួមទាំងវិធីសាស្រ្តការពារ/កម្មវិធីទៅលើជំរកសត្វព្រៃ និងផ្លូវបំលាស់ទី របស់វានៅក្នុងតំបន់គំរោង ។*

**<u>រចនាប្លង់:</u>** ជាមួយនឹងការគ្រោងយកកំពស់ទឹក២១៥ម នៅក្នុងអាងស្តុកទឹកនឹងមានផ្ទៃទឹកលិចប្រហែល ១៣៣០ ហ.ត ក្នុងនោះរួមមានប្រភេទព្រៃស្រោង វាលស្មៅ និងព្រៃគុម្ពោត។ រូងបង្ហូរទឹកក្រោមដីមានទំហំមុខកាត់៨ម និងមានប្រវែងបណ្តោយ៩៨៤៦ម ដែលត្រូវភ្ជាប់ពីកន្លែងទាញយកទឹកទៅអាគារផលិតថាមពលនឹងបង្កើតកំទេចកំទីដីនិងថ្មយ៉ាងច្រើន។ ការកាប់ព្រៃសំអាតនៃផ្ទៃចំណើរបស់ខ្សែបញ្ជូនចរន្តអគ្គិសនីមានទទឹង ៨០ម និងបណ្តោយមានប្រវែង ៦៥គ.ម ដែលភ្ជាប់ពីកន្លែងបំលែងថាមពល (switch yard) ជិតអាគារផលិតថាមពលទៅអនុស្ថានីយ៍អូរសោម នឹងធ្វើឱ្យខូចខាតព្រៃឈើមានទំហំ ៤៨០ ហ.ត។ ជាងនេះទៅទៀត ដីព្រៃរាប់រយហិកតានៅក្នុងតំបន់នឹងត្រូវខូចខាតដោយសារការសំអាតសំរាប់ការសាងសង់អាគារផលិតថាមពលអគ្គិសនី ជំរុំកម្មករ ផ្លូវចេញចូល និងទីកន្លែងចាក់អាចម៍ដី និងថ្ម។

Draft

***វិធានការបន្ធូរបន្ថយ***

- *កំពស់ទំនប់នឹងបង្រួមឱ្យនៅកំពស់ល្អប្រសើរបំផុតតាមប្លង់វិស្វកម្ម និងគិតគូដល់ទិដ្ឋភាពសេដ្ឋកិច្ច ដើម្បីកាត់បន្ថយកំពស់ទឹកជំនន់នឹងសំរួលដល់ការកាត់បន្ថយផ្ទៃលិចទឹក ។*
- *បង្រួមការសំអាតផ្ទៃចំណើរបស់ខ្សែបញ្ជូនចរន្តឱ្យនូវអប្បបរមា និង ជ្រើសរើសទីតាំងបន្ទាត់របស់ខ្សែបញ្ជូនចរន្តឱ្យនៅជិតផ្លូវដែលមានស្រាប់ជាមួយប្លង់វិស្វកម្មប្រសើរបំផុត និងគិតគូដល់ទិដ្ឋភាពសេដ្ឋកិច្ចដើម្បីកាត់បន្ថយការខូចខាតព្រៃឈើ ។*
- *បង្រួមសមាសភាពគំរោងផ្សេងៗឱ្យនៅអប្បបរមាដូចជា ការបោះជំរុំកម្មករ,ផ្លូវចេញ-ចូល,កន្លែងចាក់អាចម៍ដីឬថ្មឱ្យត្រូវទៅនឹងតម្រូវការរបស់គំរោងសំរាប់ការសាងសង់គំរោងតែប៉ុណ្ណោះ ។*

**<u>ទំនប់:</u>** ទំនប់ទាំងអស់បានសាងសង់ដោយកាត់ស្ទឹងឬទន្លេទាំងឡាយនឹងធ្វើឱ្យប៉ះពាល់ទៅលើ (i) ចលនាបំលាស់ទីរបស់ត្រី និងសត្វផ្សេងទៀតដែលរស់នៅក្នុងទឹក ទៅខ្សែទឹកខាងលើ និងចុះមកខ្សែទឹកខាង

ក្រោមរបស់ស្ទឹងឬទន្លេទាំងនោះ (ii) របបរំហូរទឹកស្ទឹង ឬទន្លេ. និង (iii) ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់គំរោង។

***វិធានការបន្ធូរបន្ថយ***

- *រំហូរទឹកយ៉ាងតិចបំផុត ៣ម៉ែ/វិនាទី នឹងត្រូវបានរបញ្ចេញទឹកជាប់ជាប្រចាំពីទំនប់តាតៃនេះ ដើម្បីរក្សាអេកូឡូស៊ីរបស់ស្ទឹងឱ្យនៅរស់។*
- *មានការស្រាវជ្រាវជាច្រើនទៅលើវារីសត្វ (សត្វដែលរស់នៅក្នុងទឹក) និងវារីរុក្ខជាតិ (រុក្ខជាតិដែលរស់នៅក្នុងទឹក) ទាំងខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមនៃទីតាំងគំរោងនឹងត្រូវបានអនុវត្តន៍ក្នុងពេលប្រតិបត្តិការគំរោង។*
- *ការទូទាត់សងអាចត្រូវបានផ្តល់ឱ្យទៅលើកម្មវិធីកសិកម្មដូចជា (១) ការចិញ្ចឹមសត្វ (២) ការដាំបន្លែ ដាំដំណាំផ្សេងៗទៀត និង (៣) ការផ្តល់ឥណទានជនបទ។*

## ខ) ដំណាក់កាលសាងសង់

**<u>ហេតុប៉ះពាល់លើព្រៃឈើ និង ជំរកសត្វព្រៃ:</u>** ព្រៃឈើ និងជំរកសត្វព្រៃ នឹងមានការខូចខាត/បាត់បង់ដោយសារសកម្មភាពសាងសង់គំរោងរួមមាន ការសាងសង់ផ្លូវចេញចូល ការសំអាតផ្ទៃអាងស្តុកទឹក សង់អាគារផលិតថាមពល សង់ជំរុំកម្មករ កន្លែងចាក់អាចម៍ដីឬថ្ម និង ការសំអាតតាមផ្ទៃចំណើរបស់ខ្សែបញ្ជូនចរន្ត។ ហើយការបាត់បង់ព្រៃឈើដោយសារសកម្មភាពគំរោងទៅលើព្រៃស្រោងប្រហែល ៣០០០ ហ.ត និងព្រៃឫស្សីលាយជាមួយព្រៃផ្សេងទៀតប្រហែល ១៣០ហ.ត។ តម្លៃរូបសាស្ត្រនៃការបាត់បង់ព្រៃឈើដោយសារគំរោងតាមការប៉ាន់ស្មានមានប្រមាណរាប់សិបលានដុល្លាអាមេរិក។ ជំរកសត្វព្រៃមួយចំនួននៅក្នុងតំបន់គឺនឹងត្រូវបានបាត់បង់ផងដែរ។

***វិធានការបន្ធូរបន្ថយ***

- *ក្រុមហ៊ុននឹងសហប្រតិបត្តិការល្អជាមួយរដ្ឋបាលព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបង្កើតគណៈកម្មការមួយគ្រប់គ្រងព្រៃឈើដែលនឹងត្រូវកាប់ក្នុងទីតាំងគំរោង។ ឧទាហរណ៍ គណៈកម្មការអាចស្នើឱ្យក្រុមហ៊ុនឯកជននានាចូលរួមដេញថ្លៃដើម្បីកាប់ព្រៃឈើ ប្រមូលឈើ និងលក់ឈើទៅទីផ្សារ។ ប្រាក់ដែលប្រមូលបានពីតម្លៃរូបសាស្ត្រនៃការកាប់ព្រៃឈើនៅក្នុងទីតាំងគំរោងជាចំណូលថវិកាជាតិ។*
- *ការកាប់ព្រៃឈើនឹងត្រូវបានធ្វើតែនៅក្នុងតំបន់ទីតាំងគំរោង ដែលសកម្មភាពសាងសង់តំរូវការ និងបន្ទាប់ពីការយល់ព្រមពីគណៈកម្មការខាងលើ។*

- *ធ្វើការហាមឃាត់ឱ្យបានតឹងរឹងបំផុតចំពោះកម្មករពីការរុករានចូលព្រៃដើម្បីបរបាញ់សត្វ ឬក៏កាប់ព្រៃឈើសំរាប់កាន់កាប់ដី ។*
- *ការដាំដើមឈើឡើងវិញក្នុងទីវាលទំនេរក្បែរតំបន់គំរោង ទីកន្លែងធ្វើរួច ( តំបន់ចាក់អាចម៍ដី ឬថ្ម ជំរុំកម្មករ តាមផ្លូវចេញចូលសំរាប់ទៅរូងបង្ហូរក្រោមដី ។ល ។) ឬនៅក្នុងតំបន់ដែលបានយល់ព្រមដោយរដ្ឋបាលព្រៃឈើក្រោយពីដំណាក់កាលសាងសង់គំរោង ។*
- *ក្រុមហ៊ុននឹងគិតគូរក្នុងការចូលរួមចំណែកដើម្បីពង្រឹងដល់ការដាំដើមឈើឡើងវិញ និងកម្មវិធីអភិរក្សដែនជំរកសត្វព្រៃ ដោយអនុលោមទៅតាមការគ្រប់គ្រងបរិស្ថាន និងតាមគោលនយោបាយនារបស់រាជរដ្ឋាភិបាលកម្ពុជា ។*

**<u>ហេតុប៉ះពាល់លើសត្វព្រៃ:</u>** គំរោងនេះនឹងមានផលប៉ះពាល់ទៅលើជីវិតសត្វព្រៃក្នុងតំបន់ ដែលបច្ចុប្បន្ននេះមានថនិកសត្វ ជាច្រើនដូចជា ដំរី ខ្លាឃ្មុំតូច ខ្លាឃ្មុំធំ ជ្រូកព្រៃ ឈ្លូស សំពោច ឆ្កែព្រៃ ប្រើស ទោម្កុដ ស្វាត្រោស និង ពង្រូល និងសត្វល្មូនមួយចំនួនដូចជា ក្រពើភ្នំ ពស់ថ្លាន់ធំ អណ្តើក និងត្រកួត ព្រមទាំងពពួកសត្វស្លាបរួមមាន សត្វកេងកងធំ ញូង មាន់ទោពណ៌ប្រាក់ និង អកត្រីក្បាលប្រផេះ ។

***វិធានការបន្ធូរបន្ថយ***

- *ការកាប់ព្រៃឈើនឹងត្រូវបានធ្វើតែនៅក្នុងតំបន់ទីតាំងគំរោង ដែលសកម្មភាពសាងសង់តំរូវការ និងបន្ទាប់ពីការយល់ព្រមពីគណៈកម្មការគ្រប់គ្រងព្រៃឈើដែលនឹងត្រូវកាប់ក្នុងទីតាំងគំរោង ។*
- *ធ្វើការហាមឃាត់ឱ្យបានតឹងរឹងបំផុតចំពោះកម្មករពីការរុករានចូលព្រៃ ដើម្បីបរបាញ់សត្វ ឬក៏កាប់ព្រៃឈើដើម្បីកាន់កាប់ដី ។*
- *ក្រុមហ៊ុននឹងសហប្រតិបត្តិការល្អជាមួយរដ្ឋបាលព្រៃឈើ និង ភ្នាក់ងារអភិរក្សនៅនឹងកន្លែង ដើម្បីដាក់ពិន័យលើបុគ្គលិករបស់គំរោងណា ដែលបានបរបាញ់សត្វព្រៃខុសច្បាប់ ដោយផ្អែកទៅលើបទបញ្ញត្តិ ឬក៏ច្បាប់ការពារសត្វព្រៃ ។*
- *សកម្មភាពជីកយកថ្ម និងដីដើម្បីសាងសង់មានដូចជា ការបំផ្ទុះ និង ការជីកកាយនឹងត្រូវកំណត់សំលេង និងរំញ័រ ដោយអនុលោមតាមស្តង់ដាខ្យល់និងសំលេងរបស់ក្រសួងបរិស្ថានក្នុងប្រទេសកម្ពុជា ។*
- *ពេលវេលាធ្វើការប្រចាំថ្ងៃជាទូទៅគឺត្រូវធ្វើនៅពេលថ្ងៃតែប៉ុណ្ណោះនៅក្នុងដំណាក់កាលសាងសង់ ។*
- *ក្រុមហ៊ុននឹងគិតគូរក្នុងការចូលរួមចំណែកដើម្បីពង្រឹងដល់ការដាំដើមឈើឡើងវិញ និងកម្មវិធីអភិរក្សដែនជំរកសត្វព្រៃ ដោយអនុលោមទៅតាមការគ្រប់គ្រងបរិស្ថាន និងតាមគោលនយោបាយនារបស់រាជរដ្ឋាភិបាលកម្ពុជា ។*

Draft

**មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ:** ដោយហេតុថាតំបន់គំរោងធ្លាប់ជាជំរុំរបស់ខ្មែរក្រហមក្នុងអំឡុងពេលសង្គ្រាមស៊ីវិល (ឆ្នាំ១៩៧០-៧៥ និង ឆ្នាំ១៩៧៩-១៩៩៣)។ អាចមាននៅសល់គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះនៅក្នុងតំបន់នោះ នឹងអាចធ្វើឱ្យមានគ្រោះថ្នាក់ទៅដល់កម្មករ និងប្រជាជនមូលដ្ឋានដែលនឹងអាចកើតមានឡើងក្នុងរយៈពេលសាងសង់គំរោង។

***វិធានការបន្ធូរបន្ថយ***

- *ការដោះគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះត្រូវបានធ្វើមុនពេលធ្វើការងារគាស់កាយដី ជាពិសេសតាមផ្លូវចេញចូលគំរោង ក្នុងទីតាំងសាងសង់ និងការដ្ឋានយកថ្ម។ ម្ចាស់គំរោងនឹងធ្វើសហប្រតិបត្តិការល្អជាមួយអាជ្ញាធរដោះមីនមូលដ្ឋាន CMAC ឬក៏ភ្នាក់ងារដោះមីនក្នុងស្រុកដទៃទៀត ដើម្បីដោះស្រាយបញ្ហានេះ។*

## គ) ដំណាក់កាលប្រតិបត្តិការគំរោង

**ហេតុប៉ះពាល់ទៅលើជំរកសត្វព្រៃ និង ជីវិតសត្វព្រៃ:** ដំណាក់កាលប្រតិបត្តិគំរោងនឹងធ្វើឱ្យប៉ះពាល់ដល់ជំរកសត្វព្រៃ និងជីវិតសត្វព្រៃនៅក្នុងតំបន់ដោយសារការរំខានពីទីតាំងអាងស្តុកទឹក និងការគ្រប់គ្រងកាកសំណល់មិនត្រឹមត្រូវនៃគំរោង។

***វិធានការបន្ធូរបន្ថយ***

- *ក្រុមហ៊ុនប្រតិបត្តិការគំរោងត្រូវមានផែនការផ្លាស់ប្តូរទូវាលជុំវិញបណ្តោះអាសន្នទាំងអស់ និងទីកន្លែងផ្សេងៗទៀត ដែលបានប្រើប្រាស់ឬបំរើសំរាប់ការសាងសង់គំរោង ដើម្បីថែរក្សាច្រករបៀងរបស់សត្វដំរី និងសត្វធំៗផ្សេងទៀត។*
- *ត្រូវធ្វើការហាមឃាត់ឱ្យបានតឹងរឹងចំពោះកម្មករ និងបុគ្គលិកប្រតិបត្តិគំរោងមិនឱ្យរុករានចូលទៅក្នុងព្រៃឬដែនជំរកសត្វព្រៃ និងតំបន់ដែលជាផ្លូវបំលាស់ទីរបស់សត្វព្រៃដើម្បីកាន់កាប់ដីធ្លី ឬក៏បរបាញ់សត្វជាពិសេសនៅក្នុងតំបន់គំរោងទាំងមូល ។*
- *ក្រុមហ៊ុនត្រូវសហប្រតិបត្តិការល្អជាមួយរដ្ឋបាលព្រៃឈើ អង្គការអភិរក្សអន្តរជាតិ CI, Wildlife Alliance, ភ្នាក់ងារអភិរក្សដទៃៗទៀត និងអាជ្ញាធរមូលដ្ឋានក្នុងខេត្តកោះកុង និងខេត្តពោធិសាត់ ដើម្បីការពារការរុករានចូលទៅក្នុងព្រៃដើម្បីកាប់ព្រៃឈើខុសច្បាប់ការរានចាប់យកដី និងការបរបាញ់សត្វនៅក្នុង និងជុំវិញតំបន់គំរោង ។*
- *ក្រុមហ៊ុននឹងគិតគូរក្នុងការចូលរួមចំណែកដើម្បីពង្រឹងដល់ការដាំដើមឈើឡើងវិញ និងកម្មវិធីអភិរក្សដែនជំរកសត្វព្រៃ ដោយអនុលោមទៅតាមការគ្រប់គ្រងបរិស្ថាន និងតាមគោលនយោបាយនារបស់រាជរដ្ឋាភិបាលកម្ពុជា។*



Draft

**<u>ហានិភ័យនៃការបាក់ទំនប់:</u>** ក្នុងអំឡុងពេលប្រតិបត្តិការគំរោងអាចនឹងមានហានិយភ័យដោយសារ គ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ សកម្មភាពភេរវកម្ម និង សង្គ្រាម។ គ្រោះធម្មជាតិរួមមាន ការរញ្ជួយផែនដី បន្ទុះភ្នំភ្លើង ឬព្យុះដ៏ធ្ងន់ធ្ងរពីឈូងសមុទ្រថៃអាចប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងទៅដល់គំរោង ដូចជាការបាក់ទំនប់ ឬការខូចខាតហេដ្ឋារចនាសម្ព័ន្ធគំរោងផ្សេងៗទៀត។ ការបាក់បែកទំនប់អាចធ្វើឱ្យខូចខាតដល់ដំណាំកសិកម្ម និងទ្រព្យសម្បត្តិរបស់សហគមន៍ដែលស្ថិតនៅខ្សែទឹកខាងក្រោម និងអាចមានគ្រោះថ្នាក់ ឬក៏រហូតដល់បាត់បង់ជីវិតដល់បុគ្គលិកគំរោង និងប្រជាជនមូលដ្ឋានដែលរស់នៅជិតឬនៅខ្សែទឹកខាងក្រោមនៃទីតាំងទំនប់។

**វិធានការបន្ធូរបន្ថយ**

- *លក្ខណៈសម្បត្តិរចនាប្លង់គំរោង នឹងមានបញ្ចូលកត្តាការពាររញ្ជួយផែនដី និងការពារព្យុះកំណាចដែលមានល្បឿនខ្លាំងនៅក្នុងតំបន់គំរោងឬក៏នៅក្នុងតំបន់ទាំងមូល ដោយអនុលោមតាមបទដ្ឋាននៃការរចនាប្លង់ថាមពលវារីអគ្គិសនី។*
- *ត្រួតពិនិត្យជាទៀងទាត់ទៅលើគុណភាពទំនប់ថាពិតជាមានភាពជាប់មាំល្អ តាមស្តង់ដារចនាប្លង់ជាក់លាក់។*
- *ត្រួតពិនិត្យជាទៀងទាត់ទៅលើសំណង់បង្ហៀរទឹកមានដំណើរការល្អដូចរចនាប្លង់ដើម មិនមានឈើឬក៏សម្ភារៈផ្សេងៗទៀតរាំងស្ទះនោះឡើយ។*
- *រចនសម្ព័ន្ធលាងបាតអាង នឹងត្រូវបានបើកពេញទំហឹងនៅពេលអាងស្តុកទឹកចាប់ផ្តើមហូរពីលើទំនប់បង្ហៀរ។*
- *ក្រុមហ៊ុននឹងបញ្ចេញទឹកច្រើនពីទីតាំងអាងស្តុកទឹកមុនពេលការរញ្ជួយដី ឬ បន្ទុះភ្នំភ្លើង ប្រសិនបើបានដឹងនូវព្រឹត្តិការណ៍ទាំងនោះមុន (ក្នុងពេលវេលាមួយដ៏សមស្រប) និងរៀបចំការពារនិងជំលៀសបុគ្គលិកគំរោង និងប្រជាជនក្នុងតំបន់ដែលអាចរងគ្រោះថ្នាក់។*
- *ក្រុមហ៊ុន នឹងធ្វើសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន នគរបាល និងភ្នាក់ងារទទួលខុសត្រូវដ៏ទៃទៀតនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារសកម្មភាពភេរវកម្មនានាក្នុងតំបន់គំរោង។*
- *ក្រុមហ៊ុននឹងត្រូវផ្តល់ព័ត៌មានឱ្យទាន់ពេលវេលាទៅដល់បុគ្គលិកគំរោង អាជ្ញាធរមូលដ្ឋាន និងប្រជាជនមូលដ្ឋាននូវរាល់ព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំទៅដល់ការបាក់ឬធ្លាយទំនប់។*
- *គាំទ្រការសង្គ្រោះបន្ទាន់សំរាប់ធ្វើការបញ្ជៀសបុគ្គលិក និងប្រជាជនពីគ្រោះមហន្តរាយនៅក្នុងតំបន់គំរោង នឹងត្រូវបានផ្តល់ឱ្យផងដែរ។*
- *ក្រុមហ៊ុន នឹងត្រូវទទួលខុសត្រូវ ដើម្បីការពារ និងទូទាត់សងចំពោះការខូចខាតទ្រព្យសម្បត្តិឬក៏បាត់បង់អាយុជីវិតដែលអាចកើតមាន ឡើងដោយសារហានិភ័យខាងលើ ដោយយោងតាមលក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគរវាងក្រុមហ៊ុន និងរាជរដ្ឋាភិបាលកម្ពុជា។*

## ៤.២ ផលប៉ះពាល់វិជ្ជមាន

គំរោងនឹងតំឡើងទួប៊ីនអគ្គិសនីដែលមានអនុភាពតំឡើង **២៤៦ មេហ្គាវ៉ាត់** និងអាចផលិតថាមពលសរុបប្រមាណជា **៨៩៨ ជីហ្គាវ៉ាត់ម៉ោង** ក្នុងមួយឆ្នាំ ហើយនឹងផ្តល់នូវនិរន្តរភាពក្នុងការផ្គត់ផ្គង់ថាមពល. ព្រមទាំងមានតម្លៃថោកជាងតម្លៃបច្ចុប្បន្នដល់អតិថិជនគ្រប់លំដាប់ថ្នាក់ ដូចជាការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម តាមលំនៅដ្ឋាន វិស័យកសិកម្ម និងវិស័យដទៃទៀត។ វាអាចឆ្លើយតបទៅនឹងតំរូវការថាមពលអគ្គិសនីរបស់កម្ពុជាក្នុងឆ្នាំ ២០១៨។

គំរោងវារីអគ្គិសនីស្ទឹងតាតៃជាប្រភពថាមពលកកើតឡើងវិញ អាចកាត់បន្ថយសំពាធទៅលើធនធានព្រៃឈើ ដូចជា ការប្រើប្រាស់ជាអុសដុត ឬធ្យូង ការកាប់ព្រៃឈើ និងការបរបាញ់សត្វព្រៃ។ គំរោងជួយក្នុងការកាត់បន្ថយការបំពុល ខ្យល់ក្នុងបរិយាកាស។ ជាងនេះទៅទៀតគំរោងនេះជួយជំរុញដល់គំរោងយន្តការអភិវឌ្ឍស្អាតនៃប្រទេសកម្ពុជា ដើម្បីទប់ស្កាត់ការផ្លាស់ប្តូរធាតុអាកាស និងអាចលក់ឥនទានកាបូនទៅឱ្យប្រទេសអភិវឌ្ឍន៏បានទៀតផង។

គំរោងវារីអគ្គិសនីតាតៃនឹងសាងសង់ផ្លូវចេញចូលថ្មីទៅកាន់ទីតាំងរបស់គំរោង ការកែលំអរផ្លូវគ្រួសក្រហម និងរចនាសម្ព័ន្ធដទៃទៀតនៅតាមបណ្តោយផ្លូវទៅកាន់ស្រុកថ្មបាំងផងដែរ។ ការកែលំអហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូបង្ហូរទឹក ស្ពាននិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតពីគំរោងវារីអគ្គិសនីស្ទឹងតាតៃ និងបង្កើននូវសក្តានុពលអេកូទេសចរណ៍នៅក្នុងស្រុកថ្មបាំង។ លើសពីនេះទៅទៀត ដោយសារហេដ្ឋារចនាសម្ព័ន្ធគំរោងខ្លួនឯងផ្ទាល់ ក៏អាចចូលរួមផ្តល់វិភាគទានដល់រចនាសម្ព័ន្ធរូបវ័ន្តដើម្បីទាក់ទាញ អ្នកសិក្សាជាតិនិងអន្តរជាតិ និងភ្ញៀវជាតិមកទស្សនកិច្ច ដើម្បីសិក្សាស្រាវជ្រាវ និងទស្សនាលើគំរោងថាមពលវារីអគ្គិសនីនេះ។

គំរោងនឹងផ្តល់ការងារឱ្យធ្វើដល់កម្មករកម្ពុជារាប់រយទៅរាប់ពាន់នាក់ ជាពិសេសទៅដល់ប្រជាជននៅមូលដ្ឋានក្នុងសហគមន៏ក្នុងអំឡុងពេលសាងសង់គំរោង។ ប្រជាជនមួយចំនួនក៏អាចរកចំណូលបានពីមុខរបរជំនួញផ្ទាល់ខ្លួនរបស់ពួកគេ ដែលទាក់ទងទៅនឹងសកម្មភាពគំរោង <u>ឧទាហរណ៏</u> ពួកគេអាចចុះកិច្ចសន្យាសំរាប់ការងារតូចៗ ដែលក្រុមហ៊ុនផ្តល់ជាកិច្ចសន្យាម៉ៅការដល់ពួកគេ។ ប្រជាជននៅក្នុងតំបន់នោះអាចរកកំរៃបានផងដែរ ដោយការលក់ផលិតផលរបស់ពួកគេនៅក្នុងទីផ្សារក្នុងមូលដ្ឋាន និងសេវាកម្មទេសចរណ៏ ។

ទុនវិនិយោគសរុបរបស់គំរោងវារីអគ្គិសនីគឺប្រហែល **៥៤០លានដុល្លាអាមេរិក** ដែលជាការចូលរួមវិភាគទានទុនឯកជនដ៏ធំមួយសំរាប់ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពលនៅក្នុងប្រទេសកម្ពុជាដើម្បីទ្រទ្រង់ការលូតលាស់នៃសេដ្ឋកិច្ចជាតិក្នុងឆ្នាំបន្តបន្ទាប់។ ទន្ទឹមនេះដែរ ដោយផ្អែកតាមការផលិតថាមពលប្រចាំឆ្នាំបាន ៨៥៨ ជីហ្គាវ៉ាត់ម៉ោង វានឹងជួយទ្រទ្រង់ដល់សកម្មភាពអភិវឌ្ឍន៏ឧស្សាហកម្ម ឬសិប្បកម្ម កសិកម្ម និងទេសចរណ៏ នៅក្នុងតំបន់ក៏ដូចជានៅក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ ដែលជំរុញដល់ការរីកចំរើនផ្នែកសេដ្ឋកិច្ចកាន់តែរឹងមាំ។ ក្រុមហ៊ុននឹងបង់ពន្ធគ្រប់ប្រភេទដល់រាជរដ្ឋាភិបាលកម្ពុជាទៅតាមកិច្ចព្រមព្រៀង និងកាតព្វកិច្ចច្បាប់វិនិយោគទុនរបស់ប្រទេសកម្ពុជា ។

Draft

## ៥. ការចូលរួមជាសាធារណៈ

ការប្រជុំពិគ្រោះយោបល់ជាសាធារណៈពីរដំណាក់កាល ត្រូវបានអនុវត្តធ្វើក្នុងអំឡុងពេលនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គោលបំណងនៃការប្រជុំពិគ្រោះយោបល់លើកទីមួយគឺ ការផ្សព្វផ្សាយព័ត៌មានគំរោងទៅដល់សហគមន៍មូលដ្ឋាន និង ពិនិត្យទៅលើបញ្ហាបរិស្ថានដែលនឹងអាចកើតមានឡើងដោយសារសកម្មភាពគំរោង។ ការរៀបចំកិច្ចប្រជុំត្រូវបានធ្វើតាមរយៈថ្នាក់ដឹកនាំសហគមន៍នៅក្នុងឃុំ និងថ្នាក់ភូមិ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីពីរត្រូវបានរៀបចំធ្វើឡើងក្រោយពីការងារទីវាលបានបញ្ចប់ និងទទួលបានលទ្ធផលនៃការសិក្សាគ្រប់គ្រាន់ត្រឹមត្រូវ ការរៀបចំរចនាប្លង់វិស្វកម្ម និង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោង ដើម្បីបង្ហាញជូនដល់អ្នកដែលពាក់ពន្ធ័ទាំងឡាយ។ អ្នកតំណាងសហគមន៍ដែលរងផលប៉ះពាល់ តំណាងមន្ទីរពាក់ព័ន្ធទាំងអស់ក្នុងខេត្ត ស្ថាប័នឯកជន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធពីថ្នាក់ជាតិ ត្រូវបានអញ្ជើញឱ្យចូលរួម។

សហគមន៍ពីរផ្សេងគ្នាត្រូវបានជ្រើសរើសយកធ្វើការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១:

- (១) ឃុំឫស្សីជ្រុំ បានរៀបចំកិច្ចប្រជុំប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៩ នៅក្នុងវត្តថ្មបាំង ដែលមានអ្នកចូលរួមសរុប ៥៩នាក់ ក្នុងនោះមានស្រីចំនួន ២៨នាក់ ។
- (២) នៅក្នុងឃុំតាតៃក្រោមបានប្រព្រឹត្តទៅនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ នៅក្នុងការិយាល័យសមាគមអេកូទេសចរណ៍ ដែលមានអ្នកចូលរួមសរុបចំនួន ៥៨នាក់ ក្នុងនោះមានស្រីចំនួន ៣៨នាក់។

សម្ភារៈដែលបានយកមកប្រើក្នុងការប្រជុំពិគ្រោះយោបល់លើកទី១ រួមមានព័ត៌មានសង្ខេបពីប្រវត្តិគំរោងជាភាសាខ្មែរ (ឧបសម្ព័ន្ធទី៧) ផែនទីទីតាំងអាងស្តុកទឹកដែលបានស្នើឡើងជាមួយនឹងកំពស់ទឹកអតិបរមា និងគំនូសបំព្រួញដែលមានសមាសធាតុផ្សេងៗច្រើនទៀត។ លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១ គឺមានសំណួរជាច្រើនត្រូវបានឆ្លើយតបដោយក្រុមសិក្សាបន្ទាប់ពីសំនួរនីមួយៗបានសួរចប់។ ប្រជាជនបានយល់ច្បាស់ពីស្ថានភាព និងសកម្មភាពរបស់គំរោង។ ពួកគេបានសង្ឃឹមថា សហគមន៍នឹងមានភ្លើងប្រើប្រាស់គ្រប់គ្រាន់ និងមានតម្លៃថោកក្រោយពេលគំរោងបានសាងសង់រួចរាល់។ អ្នកចូលរួមទាំងអស់បានលើកដៃគាំទ្រគំរោងគឺ ១០០% និងចង់បានគំរោងនេះដំណើរការក្នុងពេលឆាប់ៗនេះ។

ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២បានធ្វើនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ក្នុងសាលប្រជុំនៃសាលាខេត្តកោះកុង ដែលមានអ្នកចូលរួមសរុបចំនួន ៣៧នាក់មកពី:

- អាជ្ញាធរមូលដ្ឋានមានដូចជាមេភូមិ និងអនុភូមិ ថ្នាក់ឃុំ សមាគមសហគមន៍ និងប៉ូលីស
- មន្ទីរពាក់ព័ន្ធក្នុងខេត្ត
- សាលាខេត្ត
- អង្គការក្រៅរដ្ឋាភិបាល
- ស្ថាប័នឯកជន និង
- អ្នកតំណាងពីអន្តរក្រសួង និងមកពីថ្នាក់ជាតិ។



Draft

ក្នុងរយៈពេលនៃការប្រជុំបានបង្ហាញពីលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់គំរោងវារីអគ្គិសនីស្ទឹងតាតៃ ព្រមទាំងទិដ្ឋភាពបច្ចេកវិស្វកម្ម និងបរិស្ថាន ត្រូវបានពន្យល់ជាមួយនឹងផ្ទាំងរូបភាពយ៉ាងច្បាស់ល្អដោយប្រើសម្ភារៈបង្ហាញ (កម្មវិធី in power point, words/excels, និង ប្លង់/ផែនទី) ការប៉ាន់ស្មានលើផលប៉ះពាល់ក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការគំរោង ការរៀបចំវិធានការកាត់បន្ថយទៅលើផលប៉ះពាល់អវិជ្ជមាននីមួយៗ។ សំណួរ ការពិភាក្សា និង អនុសាសន៍ត្រូវបានអនុវត្តបន្ទាប់ពីការធ្វើបទបង្ហាញ។ អនុសាសន៍ និងសំណួរទាំងអស់ត្រូវបានកត់ត្រាដោយក្រុមសិក្សា ហើយសំណួរ និងសំណូមពរមួយចំនួនត្រូវបានឆ្លើយតបផងដែរ។

ជាទូទៅប្រជាជននៅក្នុងមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល បានស្វាគមន៍ចំពោះ គំរោងវារីអគ្គិសនីស្ទឹងតាតៃ និងបានផ្តល់អនុសាសន៍ដល់ក្រុមសិក្សា និងក្រុមហ៊ុនដូចបានរៀបរាប់នៅក្នុងជំពូកទី៨។ អនុសាសន៍ជាគន្លឹះមួយចំនួន រួមទាំងការទូទាត់គ្រប់គ្រាន់ចំពោះប្រជាជនដែលនឹងរងផលប៉ះពាល់ដោយសារគំរោង នឹងត្រូវបានផ្តល់ដោយម្ចាស់គំរោង។ អ្នកចូលរួមមួយចំនួនចង់ឱ្យក្រុមហ៊ុនអនុវត្តតាមវិធានការកាត់បន្ថយយ៉ាងមុតមាំ តាមផែនការគ្រប់គ្រងបរិស្ថាន។ អង្គការមិនមែន រដ្ឋាភិបាលបានសំណូមពរក្រុមហ៊ុនឱ្យធ្វើសហប្រតិបត្តិការល្អជាមួយ រដ្ឋបាលព្រៃឈើ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីការពារព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់។

## ៦. ផែនការគ្រប់គ្រងបរិស្ថាន

### ៦.១. ការរៀបចំស្ថាប័ន

ការអនុវត្តនូវផែនការគ្រប់គ្រងបរិស្ថានសំរាប់គំរោង នឹងត្រូវអនុវត្តដោយម្ចាស់គំរោង ក្នុងការសហប្រតិបត្តិការ ជាមួយស្ថាប័នជំនាញ ទាំងនៅក្នុងខេត្ត និងកំរិតថ្នាក់ជាតិ ។ នៅកំរិតថ្នាក់ជាតិ ដូចជាអគ្គនាយកដ្ឋានថាមពល ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល នាយកដ្ឋានអង្កេតពិនិត្យវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យ ការបំពុលបរិស្ថាននៃក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋាន ជលសាស្ត្រ និងការងារទន្លេ នៃក្រសួងធនធានទឹក និងឧតុនិយម ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធផ្សេងៗទៀត។

នៅក្នុងកំរិតថ្នាក់ខេត្ត ម្ចាស់គំរោងនឹងធ្វើសហប្រតិបត្តិការជិតស្និទ្ធជាមួយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល, មន្ទីរបរិស្ថាន, មន្ទីរធនធានទឹក និងឧតុនិយម, មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់, សាលាខេត្តកោះកុង, មន្ទីរពាក់ព័ន្ធផ្សេងៗទៀត និងអាជ្ញាធរដែនដី, អង្គការអភិរក្សអន្តរជាតិ (CI), Wildlife Alliance/WildAid ។

### ៦.២. សង្ខេបនូវផលប៉ះពាល់បរិស្ថាន និងវិធានការបន្ធូរបន្ថយ

គំរោងនេះ នឹងមានផលប៉ះពាល់ដល់ធនធានសង្គម និងធនធានធម្មជាតិនៅក្នុង និងជុំវិញតំបន់គំរោងដោយ សារតែសកម្មភាពរបស់គំរោងក្នុងដំណាក់កាលមុនពេលសាងសង់ ពេលសាងសង់ និងក្នុងដំណាក់កាលប្រតិបត្តិ។ វិធាន



Draft

ការបន្ធូរបន្ថយ នឹងត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលបានកំណត់ចំពោះសមាសភាពបរិស្ថាននីមួយៗនៅក្នុងដំណាក់កាលគំរោងផ្សេងៗគ្នា គឺមានសង្ខេបនៅក្នុងតារាង ៧.២-១ នៃរបាយការណ៍នេះ។ ភ្នាក់ងារទទួលខុសត្រូវ និងការប៉ាន់ស្មានតម្លៃសំរាប់ការទូទាត់សងលើផលប៉ះពាល់អវិជ្ជមានគឺត្រូវបានបង្កើតឡើង និងការប៉ាន់ស្មាននូវតម្លៃពិស្តារសំរាប់វិធានការបន្ធូរបន្ថយមានភ្ជាប់ជូនជាមួយក្នុងឧបសម្ព័ន្ធ៦។

## ៦.៣. សង្ខេបថវិការសំរាប់ ផ.គ.ប

ក្នុងតារាងខាងក្រោមនេះ គឺជាការសង្ខេបថវិការសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងបរិស្ថានសំរាប់គំរោងវារីអគ្គិសនីស្ទឹងតាតៃ។ ក្នុងជួរទី១ គឺរួមមានថវិកាសំរាប់វិធានការកាត់បន្ថយហេតុប៉ះពាល់នានាដែលកើតចេញពីសកម្មភាពគំរោង។ ក្រុមហ៊ុននឹងគិតគូរក្នុងការចូលរួមចំណែកដើម្បីពង្រឹងដល់ការដាំដើមឈើឡើងវិញ និងកម្មវិធីអភិរក្សដែនជំរកសត្វព្រៃ ដោយអនុលោមទៅតាមការគ្រប់គ្រងបរិស្ថាន និងតាមគោលនយោបាយនារបស់រាជរដ្ឋាភិបាលកម្ពុជា។ ថវិកានេះ នឹងប្រើប្រាស់សមរាប់គ្រប់គ្រង និងស្តារបរិស្ថានឡើងវិញ រាប់បញ្ចូលទាំងការដាំឈើឡើងវិញនៅក្នុងតំបន់ ឬនៅក្បែរខាងតំបន់គំរោង។ ប៉ុន្តែកញ្ចប់ថវិកាវិភាគទានបរិស្ថានត្រូវបានគណនាចូលទៅក្នុងតំលៃដើមនៃការផលិតថាមពលអគ្គិសនី មានន័យថា វានឹងជះឥទ្ធិពលដល់តំលៃលក់ថាមពលដែលផលិតបាន ដូចនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឱ្យរាល់ការអភិវឌ្ឍរោងចក្រវារីអគ្គិសនីមិនបញ្ចូលមូលនិធិបរិស្ថានក្នុងទុនវិនិយោគឡើយ។

| ល.រ | បរិយាយ | ប្រចាំឆ្នាំ, USD | ពេញរយៈពេលគំរោង, USD |
|---|---|---|---|
| ១ | វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន | 94,400.00 | 503,000.00 |
| ២ | ការពិនិត្យតាមដានបរិស្ថាន | 3,202.43 | 118,490.00 |
| ៣ | ការបណ្តុះបណ្តាលការគ្រប់គ្រងបរិស្ថាន | 7,640.00 | 7,640.00 |
| ៤ | ការបំប៉នសមត្ថភាពតាមរយៈការងារពេលសាងសង់ | 37,200.00 | 148,800.00 |
| ៥ | **សរុបរួម** | **142,442.43** | **777,930.00** |

# ៧. ការវាយតម្លៃសេដ្ឋកិច្ច

## ៧.១ តម្លៃធនធានធម្មជាតិ

យោងតាមការសិក្សាត្រីតាមដងស្ទឹងតាតៃផ្នែកខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមរបស់ស្ទឹងក្នុងអំឡុងពេលរដូវប្រាំង និងរដូវវស្សាចំនួនទិន្នផលត្រីសរុបគឺប្រហែល ៤៧.៧៥ តោន និងចាប់កូនត្រីនាគប្រចាំឆ្នាំបានពី ៥០០ ក្បាល ទៅ ៧០០ ក្បាល ដែលបានចាប់ដោយសហគមន៍ត្រីនាគឃុំតាតៃក្រោម។ តម្លៃត្រី ទទួលបានពីគ្រួសារអ្នកនេសាទត្រីនៅក្នុងតំបន់គំរោងអំឡុងពេលសិក្សាស្រាវជ្រាវពីខែមករាដល់ខែមេសាឆ្នាំ២០០៩ គឺ ត្រីធំៗមានតម្លៃ ៥ដុល្លា/គ.ក្រ

ត្រីមធ្យមមានតម្លៃ ២ដុល្លា/គ.ក្រ និងត្រីតូចៗមានតម្លៃ ១,៥ដុល្លា/គ.ក្រ និងមានការរំពឹងទុកថាផលិតផលត្រីប្រចាំឆ្នាំនឹងថយចុះប្រហែល៥០%ដោយសារគំរោង។ ដូច្នេះតម្លៃរូបសាស្ត្ររបស់ត្រីធម្មជាតិ ដែលបាត់បង់ដោយសារគំរោងគឺ **៥១ ២៦០,០០ដុល្លារអាមេរិក** ក្នុងមួយឆ្នាំ។

យោងតាមការសិក្សាស្រាវជ្រាវលើសេដ្ឋកិច្ចសង្គមក្នុងខែមករាដល់ខែមេសាឆ្នាំ២០០៩ បានបង្ហាញថា ការផ្គត់ផ្គង់ជីវភាពគ្រួសារសរុបប្រចាំឆ្នាំបានមកពីការនេសាទ ជាពិសេសសំរាប់ប្រជាជនដែលរស់នៅតាមដងស្ទឹង អ្នកភូមិនៅខ្សែទឹកខាងលើនៃទីតាំងទំនប់រកប្រាក់បានប្រហែល ៩០ដុល្លា/ខែ និងអ្នកភូមិនៅខ្សែទឹកខាងក្រោមនៃទីតាំងទំនប់រកប្រាក់បានប្រហែល ១៦០ដុល្លា/ខែ។ ការសិក្សាបរិស្ថានបានបង្ហាញពីការប៉ាន់ស្មានថា ប្រជាជនដែលរស់នៅខ្សែទឹកខាងក្រោមនៃទីតាំងទំនប់អាចបន្តសកម្មភាពនេសាទរបស់ពួកគេតទៅទៀតទោះបីជាមានផលប៉ះពាល់ដល់ផលិតកម្មត្រីមួយចំនួនក៏ដោយ នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការគំរោង។

គំរោងនឹងធ្វើឱ្យខូចខាតដល់ព្រៃឈើ ៣.១៣២.៤២ ហ.ត ក្នុងនោះមានព្រៃឈើបាត់បង់ជាអចិន្ត្រៃយ៍មានចំនួន ២.៩៤៩.៩១ ហ.ត និងព្រៃបាត់បង់បណ្តោះអាសន្ន ១៨២.៥១ ហ.ត។ ព្រៃឈើខូចខាតនោះមានព្រៃស្រោង ៣.០១៥ ហ.ត និងព្រៃផ្សេងៗទៀត ១១៦ ហ.ត ហើយតំលៃរូបសាស្ត្រនៃព្រៃឈើដែលនឹងត្រូវបាត់បង់គឺ ៣២.៥២០.៣១៨.០០ ដុល្លារអាមេរិក ។ តម្លៃនិរន្តរភាពគ្រប់គ្រង (រួមទាំងកំនើនប្រចាំឆ្នាំ) នៃព្រៃឈើធម្មជាតិប្រមាណជា ៧១២.៨៨៧.០០ ដុល្លាអាមេរិកក្នុងមួយឆ្នាំ តម្លៃប្រមូលអនុផលព្រៃឈើ ៣៥.៦៤៤.០០ ដុល្លាអាមេរិកក្នុងមួយឆ្នាំ និងតម្លៃបរិស្ថានពីការស្រូបយកកាបូនឌីអុកស៊ីត ១៩.៩០៤.០០ ដុល្លាអាមេរិក ក្នុងមួយឆ្នាំ។

## *៧.២ វិភាគហិរញ្ញវត្ថុ និង សេដ្ឋកិច្ចរបស់គំរោង*

ការវិភាគទេវយិតភាពហិរញ្ញវត្ថុ គឺត្រូវបានធ្វើឡើងដើម្បីវាយតម្លៃលើការប៉ះពាល់នៃការកើនឡើងនូវតម្លៃ (១០%) និងការធ្លាក់ចុះថាមពលអគ្គិសនី(១០%) ទៅលើសន្ទស្សន៍ហិរញ្ញវត្ថុ ។ ការវិភាគទេវយិតហិរញ្ញវត្ថុបានបង្ហាញថា កត្តាមិនច្បាស់លាស់វានឹងមានឥទ្ធិពលទៅលើសន្ទស្សន៍ហិរញ្ញវត្ថុ។ នៅពេលតម្លៃបានកើន ១០% ថាមពលអគ្គិសនបានថយចុះ១០% នោះតម្លៃថាមពលលក់ដុំនិងកើនដល់ ០,៧៤ដុល្លា និង ០,៨៣ដុល្លា ប៉ុន្តែអត្រា FIRR ស្ទើរតែមិនផ្លាស់ប្តូរតាមការសន្មត់ប្រាក់កម្ចីត្រូវសងត្រឡប់វិញក្នុងរយៈពេល១៥ឆ្នាំ។

យោងតាមការសងប្រាក់រយៈពេល១៥ឆ្នាំ ត្រូវបានគេប៉ាន់ស្មានថា តម្លៃលក់ដុំគឺ០,០៧៤ដុល្លា/គីឡូវ៉ាត់ម៉ោង ក្នុងអំឡុងនៃរយៈពេលប្រតិបត្តិគំរោង, អត្រាចំណូល FIRR សំរាប់ទុនវិនិយោគសរុបគឺ៩,២៥%(មុនពេលបង់ពន្ធ) និង ៨,៧១%(ក្រោយពេលបង់ពន្ធ)។ អត្រាចំណូល FIRR នៃថវិកាដើមទុនគឺ ៩,២៥%។ ការស្រង់ទុនវិនិយោគមកវិញក្នុងរយៈពេល ១៣,៩ឆ្នាំ អត្រាប្រាក់ចំណេញក្នុងការវិនិយោគគឺ ៦,៣៤% និងអត្រាពន្ធលើការវិនិយោគទុនគឺ ៧,៤៧ %។ លទ្ធផលបង្ហាញថាគំរោង នេះមានផលចំណេញយ៉ាងពិតប្រាកដ និងមានលទ្ធភាពផ្នែកហិរញ្ញវត្ថុ ។

Draft



[1] រចនាសម្ព័ន្ធគំរោងស្ថិតនៅក្នុងទឹកដីកម្ពុជា មិនអាក់ខានដំណើរការទេ ទោះបីមានជំលោះនយោបាយក្នុងប្រទេសជិតខាង ។

[2] អគ្គិសនីកម្ពុជា/រដ្ឋាភិបាលកម្ពុជានឹងចំណេញប្រាក់ ២.៥ទៅដល់១២.៨លានដុល្លា/ឆ្នាំ ធៀបនឹងបរិមាណដូចគ្នាដែលនាំចូលពីប្រទេសថៃ ។